# វិចារណកថា

សមាគមបុគ្គលិកសិក្សាខ្មែរ ហៅកាត់ថា ស.ប.ស.ខ. បច្ចុប្បន្ននេះមានសមាជិក សមាជិកាជាងមួយសែននាក់ មានការភ្ញាក់ផ្អើលយ៉ាងក្រៃលែងចំពោះការប្រកាសរបស់លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យដែលបាន អះអាងថា កម្រងសំណួររបស់ខ្លួនចំពោះគ្រូចំនួន ៤៦០នាក់ ក្នុងខេត្ត ៩ និងរាជធានី បង្ហាញពីអត្រាបោះបង់ការសិក្សា នៅកម្រិតបឋមសិក្សា មានរហូតដល់ ៤០.៨៥% មធ្យមសិក្សាបឋមភូមិ មានរហូតដល់ ៣៥.៥៥% និងមធ្យមសិក្សា ទុតិយភូមិ មានរហូត ៣២.៦៤%។

ការប្រកាសនេះ វាផ្ទុយទាំងស្រុងពីរបាយការណ៍សម្រេចជាលទ្ធផល នៃសន្និបាតក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី ១៦-១៨ ខែមីនា ឆ្នាំ២០០៩ ថ្មីៗនេះដែលមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ ព្រមទាំងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល បានរួមគ្នាវាយតម្លៃជុំវិញអត្រាឡើងថ្នាក់ អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា នៃគ្រប់ភូមិសិក្សាក្នុងតួលេខសមហេតុសមផល។

សម្រាប់សមាគមបុគ្គលិកសិក្សាខ្មែរ ស.ប.ស.ខ. សមាជិក សមាជិកាទាំងអស់គ្នា សន្និដ្ឋានថា ការប្រកាសរបស់លោក រ៉ុង ឈុន ជាការប្រកាសមានលក្ខណៈបុរេនិច្ឆ័យ គ្មានវិជ្ជាជីវៈ និងគួរឱ្យសោកស្ដាយជាទីបំផុត។

សេចក្ដីដូចជម្រាបនេះ សូមសាធារណៈមតិជាតិ និងអន្តរជាតិជ្រាបជាព័ត៌មាន តាមការគួរ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០០៩

**ជ.គណៈកម្មាធិការនាយក**

# ច្បាប់ស្តីពីការអប់រំ

## ជំពូកទី ៣
## រដ្ឋបាលកិច្ច និងការគ្រប់គ្រងការអប់រំ

**មាត្រា ៧.- ឋានានុក្រមរដ្ឋបាល និងការគ្រប់គ្រងការអប់រំ**

ក្នុងវិស័យអប់រំត្រូវមានឋានានុក្រមរដ្ឋបាល និងការគ្រប់គ្រងការអប់រំ ៤(បួន)ថ្នាក់ រួមមានថ្នាក់ជាតិ ឬ កណ្តាល ថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ និងថ្នាក់គ្រឹះស្ថានសិក្សា ។

រចនាសម្ព័ន្ធនៃឋានានុក្រមរដ្ឋបាលនិងការគ្រប់គ្រងការអប់រំ ត្រូវកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ។

**មាត្រា ៨.- ភូមិសិក្សា និងប្រភេទសិក្សា**

ប្រព័ន្ធអប់រំជាតិមាន ៣(បី) ភូមិសិក្សារួមមាន បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ។

ប្រភេទសិក្សាចែកជា ២(ពីរ) ប្រភេទសិក្សាចំណេះដឹងទូទៅ និងប្រភេទសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ។

**មាត្រា ៩.- ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃ**

វិស័យអប់រំត្រូវមានប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃវិស័យអប់រំ ដែលត្រូវបញ្ចូលការត្រួតពិនិត្យតាមដាន អធិការកិច្ច និងសវនកម្មផ្ទៃក្នុងលើការបំពេញការងារ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ មានភារកិច្ចទទួលខុសត្រូវរៀបចំយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃនេះ ។

**មាត្រា ១០.- គ្រឹះស្ថានសិក្សា**

រដ្ឋត្រូវរៀបចំឱ្យមានគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ។

ការគ្រប់គ្រងគ្រឹះស្ថានសិក្សា ត្រូវកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ។

ROYAUME du CAMBODGE • MINISTÈRE du PALAIS ROYAL

## មាត្រា ១១.- ការបង្កើតគ្រឹះស្ថានសិក្សា

នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និង/ឬរូបវន្តបុគ្គល មានសិទ្ធិស្នើបង្កើតគ្រឹះស្ថានសិក្សា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាទាំងសាធារណៈ ទាំងឯកជន តាមប្រភេទគ្រឹះស្ថានសិក្សា ។

ការបិទ ការរំលាយបញ្ចូលគ្នា ការបង្កើតជំនាញថ្មី ការបំបែក និងការប្រែក្លាយគ្រឹះស្ថានសិក្សា ត្រូវកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ។

គ្រប់គ្រឹះស្ថានសិក្សា និងថ្នាក់បណ្តុះបណ្តាលទាំងអស់ត្រូវមានអាជ្ញាប័ណ្ណអប់រំជាមុនទើបមានសិទ្ធិដំណើរការបាន ។

## មាត្រា ១២.- ប្រភេទគ្រឹះស្ថានសិក្សា

ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាទាំងអស់ ត្រូវស្របតាមបេសកកម្មអប់រំរបស់ខ្លួន ។

ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីការកំណត់ប្រភេទគ្រឹះស្ថានសិក្សា ។

## មាត្រា ១៣.- ស្វ័យភាពនៃគ្រឹះស្ថានសិក្សា

គ្រឹះស្ថានឧត្តមសិក្សា ត្រូវបានផ្តល់សិទ្ធិជាអង្គភាពមានស្វ័យភាពខាងការគ្រប់គ្រង ។

ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្អែកលើគោលការណ៍ទទួលខុសត្រូវ តម្លាភាព និងប្រយោជន៍សាធារណៈ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវចេញគោលការណ៍ណែនាំអំពីការផ្តល់សិទ្ធិជាអង្គភាពមានស្វ័យភាពក្នុងការគ្រប់គ្រង ។

## មាត្រា ១៤.- ការផ្តល់វិញ្ញាបនបត្រ និងសញ្ញាបត្រ

វិញ្ញាបនបត្រ ឬ សញ្ញាបត្រ ត្រូវបានផ្តល់ដល់អ្នកសិក្សា ដែលបានបំពេញគ្រប់លក្ខខណ្ឌតម្រូវនៃការសិក្សាដែលកំណត់ដោយគ្រឹះស្ថានសិក្សា ។

វិញ្ញាបនបត្រ ឬ សញ្ញាបត្រអាចត្រូវបានដកហូត ឬ បដិសេធដោយក្រសួង ឬ គ្រឹះស្ថានសិក្សាដែលផ្តល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រនោះ ក្នុងករណីត្រូតពិនិត្យឃើញមាន

ភាពមិនត្រឹមត្រូវក្នុងដំណើរការសិក្សារបស់អ្នកសិក្សា ឬ ភាពមិនត្រឹមត្រូវក្នុងការសម្រេចផ្តល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រដល់អ្នកសិក្សា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវចេញគោលការណ៍ស្តីពីការផ្តល់ ដកហូត ឬ បដិសេធវិញ្ញាបនបត្រ ឬ សញ្ញាបត្រដល់អ្នកសិក្សា ។

## ជំពូកទី ៤
## ប្រព័ន្ធអប់រំ

### មាត្រា ១៥.– ប្រព័ន្ធអប់រំពេញលេញ និងឯកភាព

រដ្ឋត្រូវរៀបចំឱ្យមានប្រព័ន្ធអប់រំពេញលេញ និងឯកភាព ដែលរួមមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ ។ ការអប់រំកុមារតូចជាការសិក្សាត្រៀមនៃប្រព័ន្ធអប់រំ ។

ប្រព័ន្ធអប់រំកម្ពុជា រួមមានការអប់រំសាធារណៈ និងការអប់រំឯកជន ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់ខ្លឹមសារស្តីពីប្រព័ន្ធអប់រំក្នុងលិខិតបទដ្ឋានដោយឡែក ។

### មាត្រា ១៦.– ការគាំពារ និងការអប់រំកុមារតូច

រដ្ឋត្រូវគាំពារ និងអប់រំកុមារតូច ចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សា ដែលជាទូទៅប្រព្រឹត្តនៅទារកដ្ឋាននៅសហគមន៍ ឬ នៅផ្ទះ ។

ការអប់រំមត្តេយ្យសិក្សា ត្រូវចាប់អនុវត្តមុនបឋមសិក្សា ដើម្បីត្រៀមលក្ខណៈចូលបឋមសិក្សា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់ខ្លឹមសារស្តីពីការគាំពារ និងការអប់រំកុមារតូច ។

### មាត្រា ១៧.– ការអប់រំចំណេះទូទៅ

ការអប់រំចំណេះទូទៅ ជាការចាំបាច់ដែលធ្វើឱ្យអ្នកសិក្សាមានការរីកចម្រើនចំណេះដឹង សីលធម៌ បុគ្គលិកលក្ខណៈល្អ ដោយលើកកម្ពស់សមត្ថភាពខាងផ្លូវចិត្ត បញ្ញា កាយ និង[illegible] ឱ្យចេះប្រើចំណេះដឹង និងបំណិនមូលដ្ឋាន ។




# ពុទ្ធិកធម្មយាត្រានៅឥណ្ឌា

កាលពីថ្ងៃទី ៥ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ គណៈប្រតិភូប្រទេសទន្លេមេគង្គចំនួន ៥ គឺកម្ពុជា ឡាវ ភូមា ថៃ និងវៀតណាមបានដឹកនាំសមាជិកសរុបចំនួន ១១០នាក់ ធ្វើធម្មយាត្រាពុទ្ធសាសនារួមគ្នាមួយឆ្ពោះទៅពុទ្ធបូជនីយដ្ឋានសំខាន់ៗជាច្រើននៅប្រទេសឥណ្ឌា។ ក្បួនធម្មយាត្រានេះ ធ្វើឡើងក្រោមការឧបត្ថម្ភ និងការគាំទ្ររបស់រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគី រវាងប្រទេសទន្លេមេគង្គទាំង ៥ និងប្រទេសទន្លេគង្គា (ឥណ្ឌា) លើវិស័យវប្បធម៌ព្រះពុទ្ធសាសនា ក្រោមប្រធានបទ "កិច្ចសហប្រតិបត្តិការមេគង្គ-គង្គា"។ ខ្ញុំ ខៀវ ស៊ន ជាសមាជិកម្នាក់ នៃគណៈប្រតិភូកម្ពុជា នាពេលនោះ។

នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៧ គណៈប្រតិភូធម្មយាត្រាកម្ពុជាដែលមានសមាជិក២០រូប ដឹកនាំដោយឯកឧត្តម ហ៊ីង គីមថន អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា បានចាកចេញពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅវេលាម៉ោង ១០ព្រឹក ហើយទៅដល់ទីក្រុងបាងកក (ប្រទេសថៃ) បន្ទាប់ពីហោះហើរអស់រយៈពេលមួយម៉ោងក្រោយមក។ នៅបាងកក គណៈប្រតិភូកម្ពុជាយើងបានជួបជុំជាមួយគណៈប្រតិភូនៃប្រទេសបួនទៀត មុននឹងបន្តដំណើរទៅកាន់ប្រទេសឥណ្ឌា នាព្រឹកថ្ងៃបន្ទាប់ (០៥-០៩-០៧)។ គណៈប្រតិភូធម្មយាត្រាអន្តរពុទ្ធសាសនិកបានទៅដល់អាកាសយានដ្ឋានប៉ាតៈណា (Partna) ក្រោយពីធ្វើដំណើររួមគ្នាអស់ពេលបីម៉ោង។ នៅទីនោះ គណៈប្រតិភូទាំង៥ប្រទេសបានទទួលកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ បំផុតពីអាជ្ញាធរក្រុងប៉ាតៈណា មន្ត្រីរដ្ឋ និងរដ្ឋាភិបាលរដ្ឋប៊ីហារ (Bihar) និងមន្ត្រីទេសចរណ៍រដ្ឋប៊ីហារ។ នៅទីនោះដែរ ក្រុមអ្នកយកព័ត៌មាន អ្នកថតរូប វិទ្យុ និងទូរទស្សន៍ជាច្រើនបានមកយកព័ត៌មាន សម្ភាស និងថតរូបយ៉ាងមមាញឹក។ គណៈប្រតិភូយើងបានស្នាក់នៅក្នុងក្រុងប៉ាតៈណាមួយយប់ដោយបានចូលរួមក្នុងពិធីជប់លៀងអាហារថ្ងៃត្រង់ និងល្ងាចជាកិត្តិយសដែលរៀបចំឡើងដោយឯកឧត្តមអភិបាលរដ្ឋប៊ីហារ និងប្រធានរដ្ឋមន្ត្រីនៃរដ្ឋប៊ីហារ។ ចាប់ពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០០៧ គណៈប្រតិភូធម្មយាត្រាអន្តរពុទ្ធសាសនិកបានចូលទស្សនា និងធ្វើពិធីនមស្ការពុទ្ធបូជនីយដ្ឋាន និងមណ្ឌល ទេសចរណ៍ទាំងឡាយនៃរដ្ឋប៊ីហារ និងរដ្ឋឧត្តរប្រទេស (Uttar Pradesh: UP) ជាបន្តបន្ទាប់។

ពុទ្ធបូជនីយដ្ឋានសំខាន់ៗដែលគណៈប្រតិភូយើងបានទស្សនា និងធ្វើសក្ការបូជា នៅរដ្ឋទាំងពីរខាងលើរួមមាន :

## នៅក្រុងប៉ាតៈណា និងពោធិគយា (Bodhgaya) នៃរដ្ឋប៊ីហារ

### ក្រុងប៉ាតៈណា (អតីតបាដលីគ្រាម ឬក្រុងបាលីបុត្រ)

ជារដ្ឋធានីនៃរដ្ឋប៊ីហារ ស្ថិតនៅលើឆ្នេរទន្លេគង្គា ជាទីដែលអង្គព្រះសម្ពុទ្ធបានទ្រង់យាងឆ្លងកាត់ទន្លេនេះ មកផ្សព្វផ្សាយព្រះធម៌របស់ព្រះអង្គនៅទីនេះ និងជាទីដែលព្រះបាទអជាតសត្តុនៃនគរមគធៈ បានរើព្រះរាជធានីពីរ៉ាជី (Rajgir អតីតក្រុងរាជគ្រឹះ) មកតាំងនៅទីនេះ កាលពីសតវត្សទី៦ មុនគ.ស.។

### ពោធិគយា

ស្ថិតនៅចំងាយ ១១៥គ.ម. ពីប៉ាតៈណា ជាទឹកដីដ៏មានជីជាតិ មានពណ៌បៃតងស្រស់ ដោយសារការប្រស់ព្រំនៃស្ទឹងផល្គុ ឬនេរញ្ជណា (នេរញ្ជរា)។ ទីនេះហើយដែលព្រះយុវតាបសសិទ្ធត្ថ ទ្រង់បានជ្រើសរើសជាទីតាំងសម្រាប់ពិចារណា និងដោះស្រាយនូវប្រស្នាដ៏ធំមួយ គឺសេចក្ដីទុក្ខរបស់មនុស្សជាតិ រហូតបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ។

ចេតិយមហាពោធិ ដែលមានកម្ពស់ ៥២ម៉ែត្រ កប់ក្នុងមេឃពណ៌ខៀវស្រងាត់ ឈររឹងមាំនៅជាប់ដើមពោធិព្រឹក្ស ជាទីដែលព្រះសិទ្ធត្ថៈទ្រង់បានសម្រេចនូវគុណធម៌ខ្ពស់ក្រៃលែងលើសមនុស្ស និងទេវតាទាំងឡាយ នៅលើរតនបល្ល័ង្កដ៏ឧត្ដម។ ចេតិយតូចៗជាច្រើនលេចឡើងជុំវិញចេតិយមហាពោធិ កណ្ដាលទីលានពណ៌បៃតង ស្ថិតក្នុងបរិយាកាសស្ងប់ស្ងាត់ត្រជាក់ល្ហឹម ដែលយូរៗម្ដង សូរស័ព្ទព្រះធម៌លាន់ឮគ្រលួចកប់ពួដ៏អាកាស ជាទីគ្រឿងប្រកាសនូវសច្ចធម៌ និងសេចក្ដីស្ងប់របស់អង្គព្រះសម្ពុទ្ធ។ គឺជាទីដែលនាំចិត្តពុទ្ធសាសនិកទាំងឡាយឱ្យកើតសេចក្ដីជ្រះថ្លាចំពោះព្រះសម្ពុទ្ធ និងសាសនារបស់ព្រះអង្គក្រៃពេកណាស់។



**ពុទ្ធគយា** : កន្លែងព្រះអង្គត្រាស់ដឹង

នៅទីនេះ គណៈប្រតិភូខ្មែរយើងបានរួមគ្នាសូត្រធម៌នមស្ការ និងធ្វើសមាធិតាមកាលគួរ។ យើងបានទស្សនាឋានទីខ្លះទៀត មានទីតាំងដើមអជបាលនិគ្រោធ (កន្លែងព្រះពុទ្ធទ្រង់គង់ចំរើនកម្មដ្ឋាន) និងស្រះមុជ្ជលិន (កន្លែងដែលមុជ្ជលិននាគរាជ ពេនថ្វាយព្រះពុទ្ធអង្គគង់ពីលើ និងបើកពពាការពារព្រះអង្គ)ជាដើម ដែលនៅក្បែរទីនោះ។ ឆ្ងាយពីនោះបន្តិចនៅក្បែរស្ទឹងផល្គុ (នេរញ្ជណា ឬនេរញ្ជរា) យើងបានឃើញទីតាំងអតីតលំនៅស្ថានរបស់បុត្រីមេដឹកនាំសេនានិគម គឺនាងសុជាតា ដែលកាលនោះបានថ្វាយចង្ហាន់ចំពោះតាបសសិទ្ធត្ថ មុនពេលបានត្រាស់ជាព្រះពុទ្ធ។

### នាលន្ទា[១] មហាវិហារ

ស្ថិតនៅចម្ងាយ៨០គ.ម. ពីពោធិគយា។ នៅទីនេះ ព្រះពុទ្ធអង្គទ្រង់ធ្លាប់យាងគង់នៅជាញឹកញាប់នៅក្នុងព្រៃអម្ពវ័ន (mango grove) របស់បាវារិកសេដ្ឋី (Setthi Pavarika)។ ព្រះសារីបុត្របានសម្រេចអរហត្ត និងអស់ព្រះជន្មនៅទីនេះ។ ព្រះបាទអសោកបានយាងមកថ្វាយបង្គំព្រះសារីរិកធាតុរបស់ព្រះសារីបុត្រ និងបានកសាងស្តូបដ៏ធំមួយនៅលើ

(១) នាលន្ទា (Nalanda) < ន (na) + អលំ (alam) + ទា (da) : ឱ្យមិនចេះល្មម

ទីបញ្ចុះព្រះអដ្ឋិធាតុរបស់ព្រះអង្គ (សារីបុត្រ) នៅទីនេះសម្រាប់ជាទីសក្ការៈ។ សព្វថ្ងៃនេះ នាលន្ទាជាតំបន់មរតករបស់ពិភពលោក។ តំបន់នេះលាតសន្ធឹងលើផ្ទៃដី ១៤ហិកតារមានវត្តអារាមបាក់បែកចំនួន ១១ និងវិហារ ៥។ ភាពល្បីល្បាញនៃនាលន្ទាមហាវិហារ កើតមានបន្ទាប់ពីការគាស់កកាយឃើញត្រាផ្លូវការមួយដែលឆ្លាក់អក្សរថា "Sri Nalanda Mahavihara Arya Bhikshu Sanghasas (ព្រះភិក្ខុសង្ឃទាំងឡាយនៃមហាវិហារស្រីនាលន្ទា)" កាលពីទសវត្សរ៍ឆ្នាំ ១៨៦០ ធ្វើឡើងដោយក្រុមបុរាណវត្ថុវិទូ ដឹកនាំដោយ Alexander Cunningham (អង់គ្លេស)។

យ៉ាងណាក៏ដោយ នាលន្ទា ធ្វើឱ្យយើងមានក្ដីរំភើបស្ញប់ស្ញែងចំពោះភាពរុងរឿងនៃការសិក្សាព្រះធម៌នៃអង្គព្រះសម្ពុទ្ធ នាអតីតកាលនៅប្រទេសឥណ្ឌា។

<u>រ៉ាជី (Rajgir)</u>

ជាអតីតក្រុងរាជគ្រឹះ ដែលកាលនោះជារាជធានីនៃនគរមគធៈ សោយរាជ្យដោយព្រះបាទពិម្ពិសារ។ ក្រុងរាជគ្រឹះពទ្ធព័ទ្ធដោយភ្នំ ៥ និងគុហាជាច្រើន ដែលមានឈ្មោះហៅតាមភាសាខុសគ្នា។ មុន និងក្នុងជំនាន់ពុទ្ធកាល ភ្នំ និងគុហាទាំងនេះ ជាទីស្វែងរកធម៌របស់គណាចារ្យ និងមេលទ្ធិផ្សេងៗរាប់ចាប់ពីលទ្ធិរូបធាតុនិយម (materialism) នៃនិកាយចរវាកៈ (Charavaka School) ជំនាន់ដើមរហូតដល់បរមត្ថវិទ្យា (metaphysics) នៃទស្សនវិទូឧបនិស័ទ។ ដូចគណាចារ្យឯទៀតដែរ ព្រះសិទ្ធត្ថក៏បានស្វែងរកសច្ចធម៌ និងផ្លូវរំលត់ទុក្ខក្នុងសំណាក់តាបសពីររូបនៅទីនេះដែរ។ ប៉ុន្តែភាពស្ងប់ស្ងាត់ (សង្រួម) និងកាយវិការដ៏សមសួនរបស់ព្រះអង្គ បានធ្វើអ្នកនគរមគធៈ ទាំងស្ដេច ទាំងរាស្ត្រ ចាប់អារម្មណ៍យ៉ាងខ្លាំង។

រ៉ាជី ឬរាជគ្រឹះ មានចម្ងាយ ១១គ.ម ពីនាលន្ទា ៧០គ.ម ពីពោធិគយា ១០០គ.ម ពីប៉ាត់ៈណា។ គេអាចមើលឃើញទិដ្ឋភាពទាំងមូលនៃអតីតរាជធានីដ៏ល្បីល្បាញនេះ ពីលើកំពូលភ្នំរត្នៈគិរី (Ratnagiri) ដោយជិះកៅអីព្យួរនឹងខ្សែកាបទាញឡើងកំពូលភ្នំ (Chairlift)។

<u>**នៅក្រុងពារាណសី** (Varanasi)(១) **រដ្ឋឧត្តរប្រាដេស (ឧត្តរប្រទេស** Uttar Pradesh :UP)</u>

ធ្វើដំណើរអស់ចម្ងាយផ្លូវប្រមាណ ២៤០គ.ម ពីប៉ាត់ៈណា តាមរថយន្តទេសចរណ៍យើងបានទៅដល់ក្រុងពារាណសី ដែលជាទីក្រុងពិសិដ្ឋរបស់ពួកហិណ្ឌូ។ ពុទ្ធបូជនីយដ្ឋានសំខាន់ៗដែលយើងបានធ្វើធម្មយាត្រានៅទីនោះរួមមាន :

<u>សារនាថ (Sarnath)</u>

ស្ថិតនៅចម្ងាយ ១០គ.ម ពីក្រុងពារាណសី។ ក្រោយពេលបានត្រាស់ដឹង ព្រះសក្យមុនីគោតម ទ្រង់បានធ្វើពុទ្ធដំណើរអស់ ២៥០គ.ម ឆ្លងកាត់ទន្លេគង្គាពីពោធិគយា ដើម្បីតាមរកតាបស៥រូប ដែលបានតស៊ូជាមួយព្រះអង្គក្នុងការស្វែងរកមោក្ខធម៌ ហើយបានចាកចេញពីព្រះអង្គ នៅពេលបានឃើញព្រះអង្គលុះចោលអត្តកិលមថានុយោគ (ការធ្វើបាបខ្លួន) ឬទុក្ករកិរិយាមកសោយចង្ហាន់វិញ។ ទ្រង់បានជួបតាបសទាំង៥នៅឧទ្យានមិគទាយវ័ន ឬឥសិបតនៈ ដែលក្រោយមករហូតទល់ឥឡូវ ទីនេះគេហៅថា សារនាថ តាមនាមរបស់ព្រះពោធិសត្វសារង្គនាថៈ (Saranganatha)(២)។ ព្រះអង្គបានសម្ដែងធម្មចក្កប្បវត្តនសូត្រ ជាបឋមទេសនាប្រោសតាបស ៥រូប។ នៅសារនាថ ព្រះអង្គទ្រង់បានបង្កើតគណៈសង្ឃ (Sangha) ដំបូងជាមួយភិក្ខុ ៥អង្គ (អតីតតាបស ៥រូប) ជាសាវ័ករបស់ព្រះអង្គ និងបុត្ររបស់ពាណិជម្នាក់ នៅដែនកាសី

(១) ពារាណសី ជួនកាលគេហៅថា បេណារ៉េស (Benaras) និង កាសី (kashi) ផងដែរ។

(២) នាមពោធិសត្វក្នុងពុទ្ធសាសនាមហាយាន

ឈ្មោះ យស។ សារនាថ ជាទីតាំងដំបូងបង្អស់ដែលព្រះពុទ្ធសាសនាត្រូវបានប្រតិស្ឋានឡើង។ សារនាថមានកិត្តិនាមល្បីល្បាញ នៅក្នុងរាជ្យព្រះបាទអសោក (Emperor Ashoka)។ សសរស្តម្ភព្រះបាទអសោកមានរូបសីហៈបួនត្រូវបានរកឃើញនៅសារនាថ នៅឆ្នាំ១៩០៤។ ព្រះសង្ឃពុទ្ធសាសនា និងសិល្បៈពុទ្ធសាសនាត្រូវបានគោរពបូជា និងលើកតម្កើងខ្ពស់រហូតមក ដល់សតវត្សទី១២។ នៅឆ្នាំ១១៩៤ ក្រុងពារាណសី និងសារនាថត្រូវពួកមូស្លីម (Muslim) ឈ្លានពាន និងវាយកម្ទេច ចោលស្ទើររាបដល់ដី។ នៅពេលនោះ សំឡេងសូត្រធម៌របស់ព្រះសង្ឃត្រូវបាត់បង់ពីសារនាថទៅពួនៅប្រទេសឯទៀតៗស្ទើរទាំងអស់។ ៧០០ឆ្នាំក្រោយមក ក្រុមបុរាណវត្ថុវិទូមួយក្រុមរបស់អង់គ្លេស ដឹកនាំដោយ Alexander Cunningham បាន ស្រាវជ្រាវរុករកសារនាថឡើងវិញ បើកចំហរទ្វារប្រវត្តិសាស្ត្រឥណ្ឌាពីបុរាណដែលគេបំភ្លេចចោលឱ្យទូលាយ។ បច្ចុប្បន្ន ឥណ្ឌាបានយករូបសសរស្តម្ភព្រះបាទអសោក តំណាងការផ្សាយទៅគ្រប់ទិសទាំង ៤ នៃធម៌ព្រះពុទ្ធជាសញ្ញាជាតិ។

ទីស្ថានសំខាន់ៗដែលយើងបានឃើញ និងបានធ្វើសក្ការបូជានៅសារនាថ គឺ :

- **ស្តូបធមេខ** (Dhamekh Stupa) : មានរាងជាស៊ីឡាំងកសាងដោយព្រះបាទអសោក ឧទ្ទិសដល់ទីដែលព្រះពុទ្ធសំដែងធម្មចក្កប្បវត្តនសូត្រប្រោសភិក្ខុ ៥អង្គ។
- **ព្រៃឥសិបតនមិគទាយវ័ន** : ព្រៃដែលព្រះចៅក្រុងពារាណសី ទ្រង់ឱ្យអភ័យដល់សត្វម្រឹគ
- **មូលគន្ធកុដិ** (Mulgandhakuti) : កន្លែងដែលព្រះពុទ្ធទ្រង់គង់ចាំព្រះវស្សានៅសារនាថ។ នៅទីនេះដែរ គេបានកសាងវិហារមួយ ឈ្មោះមូលគន្ធកុដិវិហារដែលមានបញ្ចុះព្រះសារីរិកធាតុរបស់ព្រះពុទ្ធរកឃើញនៅតាក់ស៊ីឡា (តក្កសីលា Taxila)។ នៅក្រៅវិហារនេះ គឺដើមពោធិព្រឹក្សមានមែកសាខាជានិមិត្តរូបនៃដំណើរវិលមកវិញនៃព្រះពុទ្ធសាសនានៅឥណ្ឌា ទោះជា មិនរឹងប៉ឹងមាំមួនដូចជំនាន់ពុទ្ធកាលក៏ដោយ។



**សារនាថ** : កន្លែងព្រះអង្គប្រោសបញ្ចវគ្គី

- **ចៅខាន់ឌិ** (Chaukhandi) : ស្ថិតលើកូនភ្នំមួយ ជាស្តូបតំណាងទីកន្លែងដែលព្រះពុទ្ធទ្រង់បានជួបតាបស ៥រូបដំបូងក្នុងដំណើរយាងទៅកាន់សារនាថ។

ក្រៅពីពុទ្ធដ្ឋាន ដូចបានរៀបរាប់ដោយសង្ខេបខាងលើនេះ គណៈប្រតិភូយើងបានចូលរួមសកម្មភាពវប្បធម៌ និងទស្សនាមជ្ឈមណ្ឌលសំខាន់ៗទាំងឡាយរបស់ឥណ្ឌា មានជាអាទិ៍គឺ :

- បានចូលរួមសម្តែងសិល្បៈចម្រៀង របាំប្រពៃណីរបស់ប្រទេសនីមួយៗក្នុងកម្មវិធីវប្បធម៌ និងបានទស្សនាឆាកល្ខោនរឿងពុទ្ធប្រវត្តិដែលសម្តែងដោយសិល្បករ សិល្បការិនីឥណ្ឌាល្បីៗនៅរដ្ឋទាំងពីរ
- បានទស្សនាសារមន្ទីរ ប្រវត្តិសាស្ត្រ សិល្បៈវប្បធម៌នានារបស់ឥណ្ឌា។
- បានទស្សនាបន្ទាយ Ramnagar (សំណល់ពីអាណានិគមអង់គ្លេស) ដែលស្ថិតនៅលើមាត់ទន្លេគង្គា។

- បានទស្សនាមណ្ឌលផលិត និងលក់កំណាត់ សំលៀកបំពាក់សូត្រដែលជាផលិតផលល្បីល្បាញរបស់ឥណ្ឌា។
- បានចូលរួមស្ដាប់មតិអន្តរកម្មរបស់អ្នកប្រាជ្ញ និងសាស្ត្រាចារ្យផ្នែកការសិក្សាភាសាបាលី និងព្រះពុទ្ធសាសនា នៅសាកលវិទ្យាល័យ ហិណ្ឌូពារាណសី (Benaras Hindu Uhiversity) ។
- បានធ្វើដំណើរតាមនាវ៉ា ទស្សនាទិដ្ឋភាពវប្បធម៌ហិណ្ឌូប្លែកៗ (ការបូជាសព ការបូជាព្រះគង្គា...) នៅតាមដងទន្លេគង្គា។
- បានចូលរួមទស្សនាវត្តខ្មែរបណ្ដោះអាសន្ននៅរដ្ឋប៊ីហារ និងបានប្រគេនថវិកាសម្រាប់បន្តការកសាងវត្ត ចំពោះសមណនិស្សិតខ្មែរ (សម្រាប់តែគណៈប្រតិភូខ្មែរប៉ុណ្ណោះ) ។ល។

គណៈប្រតិភូធម្មយាត្រា បានចាកចេញពីអាកាសយានដ្ឋានក្រុងពារាណសី ទៅកាន់ទីក្រុងបាងកកនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ក្នុងដំណើរវិលត្រឡប់ទៅកាន់ប្រទេសរៀងៗខ្លួនវិញ ដោយនាំមកជាមួយនូវសេចក្ដីរំភើបសោកស្ដាយ អាឡោះអាល័យពន់ពេក។

យើងរំភើបចិត្តណាស់ ដោយសារថា អង្គព្រះសម្មុទ្ធដែលបានបរិនិព្វានជាងពីរពាន់ប្រាំរយឆ្នាំកន្លងទៅហើយ ហាក់ដូចជាកំពុងយាងជាមួយយើង ទទួលសក្ការបូជាពីយើង។ យើងសោកស្ដាយអាឡោះអាល័យដោយសារថា នៅមានពុទ្ធដ្ឋានសំខាន់ៗឯទៀតៗ ដូចជា ទីដែលព្រះពុទ្ធទ្រង់ចូលកាន់មហាបរិនិព្វាន នៅកុសិនារា (កុសិណាហ្គារ) និងទីដែលទ្រង់ប្រសូតនៅលុម្ពិនី (ព្រំដែនឥណ្ឌា-នេប៉ាល់) ដែលយើងពុំបានទស្សនានៅឡើយ ដោយសារកម្មវិធីមានកំណត់ពេល។

យ៉ាងណាក៏ដោយ ធម្មយាត្រានេះ ធ្វើឱ្យខ្ញុំបានឃើញផ្ទាល់ភ្នែកនូវទឹកដីពុទ្ធភូមិ ព្រឹត្តិការណ៍ព្រះពុទ្ធសាសនាតាំងពីអតីតកាលមកបច្ចុប្បន្នកាល និងជីវភាពពិតរបស់ពលរដ្ឋឥណ្ឌាបច្ចុប្បន្ន។ ខ្ញុំមានអារម្មណ៍ក្កកក្តួលយ៉ាងខ្លាំងនៅពេលមើលឃើញថា ព្រះពុទ្ធសាសនាមានប្រភពនៅឥណ្ឌា តែពលរដ្ឋឥណ្ឌាភាគច្រើនមិនយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនាដូចពួកយើងសោះ។ ប្រៀបធៀបជីវិតគ្រប់បែបរបស់ពលរដ្ឋឥណ្ឌា និងជីវិតរបស់ព្រះពុទ្ធ ឥណ្ឌាសមជាទឹកដីពុទ្ធភូមិឥតខ្ចោះ ព្រោះឥណ្ឌាមានចំរុះដោយវប្បធម៌ អរិយធម៌គ្រប់ពណ៌សំបុរ និងមានចំណាស់បំផុតក្នុងពិភពលោក៕



**ឧទ្យានលុម្ពិនី** : កន្លែងព្រះអង្គប្រសូត ប្រទេសនេប៉ាល់



**កុសិនារា** : ទីដែលព្រះពុទ្ធទ្រង់ចូលកាន់មហាបរិនិព្វាន

**លោក ខៀវ ស៊ិន**

# សកម្មភាពពុទ្ធសាសនាកាត់បន្ថយភាពក្រីក្រ (ត)

## ២.១ ការអប់រំ

### ក-អប់រំសីលធម៌

ជារៀងរាល់ថ្ងៃ៨កើត-៨រោច ថ្ងៃ១៥កើត និងថ្ងៃ១៥ ឬ១៤រោច នៅតាមវត្តអារាមនានា ក្នុងព្រះរាជាណាចក្រកម្ពុជា តែងមានឧបាសក ឧបាសិកា ទាយក ទាយិកា យុវជន យុវនារី កុលបុត្រខ្មែរទៅវត្តសមាទានសីល៥ សីល៨ ឬសីល១០ តាមសទ្ធាជ្រះថ្លារៀងៗខ្លួន។ ព្រះសង្ឃតែងអប់រំពីរបៀបនៃការកាន់សីល និងអានិសង្សផ្សេងៗរបស់សីល ដែលនាំមកនូវផលប្រយោជន៍សម្រាប់ខ្លួន និងសង្គម។ ចំណែកព្រះសង្ឃក៏ដូចគ្នា គឺរៀងរាល់ថ្ងៃ១៥កើត ថ្ងៃ១៥ ឬ១៤រោច ព្រះគ្រូចៅ អធិការ ព្រះថេរៈ ឬគណៈសង្ឃក្នុងវត្តនីមួយៗបានចូលរួមធ្វើឧបោសថ និងផ្ដល់ឱកាសអប់រំសីលធម៌ ក្នុងភាពជាអ្នកបួសដល់ភិក្ខុសាមណេរទាំងឡាយរៀងរាល់ថ្ងៃឧបោសថសីល វៀរលែងតែមានករណីចាំបាច់។

ទន្ទឹមនឹងនេះ ព្រះសង្ឃក៏បានចូលរួមអប់រំសីលធម៌ដល់សិស្សានុសិស្សនៅតាមបណ្ដាសាលារៀនមួយចំនួនទាំងនៅក្នុងទីក្រុង ជនបទ និងសហគមន៍ផ្សេងៗនៅតាមមូលដ្ឋានឱ្យប្រព្រឹត្តល្អដោយកាយ វាចាចិត្ត ក្នុងទិសដៅលើកកម្ពស់សីលធម៌សង្គមដែលកំពុងតែមានការថយចុះ ឱ្យមានភាពល្អប្រសើរឡើងវិញ។

### ខ-អប់រំសុជីវធម៌

ព្រះសង្ឃតែងតែអប់រំទូន្មានកុលបុត្រ កុលធីតាខ្មែរអំពីសុជីវធម៌នៃការរស់នៅយ៉ាងថ្លៃថ្នូរក្នុងសង្គមដូចជា អប់រំឱ្យចេះគោរពរៀមច្បង គោរពចាស់ព្រឹទ្ធាចារ្យ មាតាបិតា គោរពលោកគ្រូ អ្នកគ្រូ...។

### គ-អប់រំផ្លូវចិត្ត

ព្រះសង្ឃបានអប់រំប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈទាំងអស់ មិនថាព្រះរាជា នាម៉ឺន មន្ត្រី ឬប្រជាពលរដ្ឋតូចតាចឡើយ គឺអប់រំឱ្យចេះមានចិត្តមេត្តា ករុណា មុទិតា និងឧបេក្ខា ចំពោះគ្នាទៅវិញទៅមក មិនត្រូវបៀតបៀនគ្នា រំលោភសិទ្ធិគ្នាឡើយ។ នៅពេលប្រជាពលរដ្ឋមានទុក្ខព្រួយអ្វីមួយ តែងទៅពឹងពាក់ព្រះសង្ឃឱ្យជួយពន្យល់អប់រំចិត្ត ឱ្យស្គាល់ពីហេតុផលពិតដែលកើតឡើងចំពោះខ្លួន និងនៅក្នុងសង្គម ឬបង្ហាត់បង្រៀនវិបស្សនា ចម្រើនភាវនាអប់រំចិត្តឱ្យស្ងប់រំងាប់ ចាកអកុសលធម៌ផ្សេងៗនៅក្នុងលោក។

ក្នុងសកម្មភាពអប់រំសីលធម៌ សុជីវធម៌ និងការអប់រំចិត្តនេះដែរ នៅពុទ្ធមណ្ឌលសុខុមាលភាពកុមារ (វត្តទួលតាឯក ខេត្តបាត់ដំបង) មានការរៀបចំកម្មវិធីមួយ គឺកម្មវិធី "ពុទ្ធសាសនា និងការអប់រំសីលធម៌" ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ ២០០៧ ដល់ ថ្ងៃទី៣០ ខែឆ្នាំដដែលក្នុងគោលបំណង :

- ជួយយុវវ័យ កុមារា កុមារី ឱ្យមានឱកាសសិក្សា និងប្រតិបត្តិនូវសីលធម៌ព្រះពុទ្ធសាសនា ស្គាល់ពិធីបុណ្យនានាក្នុងព្រះពុទ្ធសាសនា និងសីលធម៌សង្គមឱ្យបានកាន់តែច្បាស់។
- ចង់ឃើញយុវវ័យ កុមារា កុមារី មានវិន័យសីលធម៌ស្អាតស្អំ ចេះគោរព និងធ្វើតាមច្បាប់។
- បណ្ដុះយុវវ័យ កុមារា កុមារី ឱ្យក្លាយខ្លួនជាកូនល្អ សិស្សល្អ ប្រជាពលរដ្ឋល្អ និងជាពុទ្ធសាសនិកល្អ ព្រមទាំងបង្កើនការស្រឡាញ់ជាតិ សាសនា ព្រះមហាក្សត្រ។

- ធ្វើឱ្យយុវវ័យ កុមារា កុមារី ស្គាល់នូវតម្លៃសិល្បៈ ប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ អរិយធម៌ជាតិរបស់ខ្លួន និងបង្កើនការជួយថែរក្សាវប្បធម៌ឱ្យបានគង់វង្សតរៀងទៅ
- ហ្វឹកហាត់យុវវ័យ កុមារា កុមារី ឱ្យមានចរិយាមារយាទរស់នៅល្អប្រចាំថ្ងៃ ប្រកបដោយ សុជីវធម៌ ចេះការពារខ្លួនឱ្យផុតពីគ្រឿងញៀន និងជំងឺឆ្លងផ្សេងៗ
- ជួយពង្រឹងស្នេហភាព និងសន្តិសុខក្នុងគ្រួសារ និងសង្គម ។

កម្មវិធីនេះមានបីវគ្គ ក្នុងមួយវគ្គៗមានរយៈពេល១០ថ្ងៃ មានកុលបុត្រកុលធីតាជាសិក្ខាកាមបានបួសរៀន ក្នុងរយៈពេលទាំង បីវគ្គនោះមានចំនួន ១៣៩រូប កុមារីមាន ៣៨រូប[១] ។

## ២.២ ការបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្នុងការអប់រំផ្តល់ជំនាញវិជ្ជាជីវៈ ព្រះសង្ឃបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ចំណេះដឹងតាមរយៈការបង្ហាត់ បង្រៀនភាសាបរទេស មានភាសាអង់គ្លេសជាដើម និងការផ្តល់ជំនាញផ្សេងៗទៀត ដូចជាការបង្កើតក្រុមភ្លេង ជាងឈើ ជាងកំបោរ ជាងគំនូរ ជាងចម្លាក់ និងហត្ថកម្ម សិប្បកម្មផ្សេងៗទៀតនៅតាមសហគមន៍ ឬវត្តអារាម ឬបញ្ជូនប្អូនៗកុមារឱ្យ ទៅសិក្សារៀនសូត្រនៅតាមសាលារដ្ឋផ្សេងៗ ដើម្បីសិក្សានូវមុខវិជ្ជាជំនាញជីវៈផ្សេងៗតាមសម័យនិយម ដោយជួយឧបត្ថម្ភទាំងសិក្ខូបករណ៍ ទាំងសំលៀកបំពាក់ អាហារូបត្ថម្ភ និងទីស្នាក់នៅ ។

## ២.៣ កុមារកំព្រា ក្មេងអនាថា និងជនងាយរងគ្រោះ

ព្រះសង្ឃតែងយកព្រះទ័យទុកដាក់ជួយសង្គ្រោះកុមារកំព្រា ក្មេងអនាថា ដែលឪពុកម្តាយស្លាប់ចោលដោយជំងឺអេដស៍ជាដើម ឬដោយសារការបែកបាក់គ្នារវាងឪពុកម្តាយ និងជនងាយរងគ្រោះមួយចំនួនដោយសារតែភាពក្រីក្រតោកយ៉ាក ។

នៅក្នុងសកម្មភាពនេះដែរ ព្រះសង្ឃវត្តច្បារអំពៅបានរាយការណ៍ពីសកម្មភាពការងារស្ម័គ្រចិត្ត ដៃគូអង្គការអូស្ត្រាលីសង្គ្រោះកុមារ ដែលបានអនុវត្តកន្លងមករហូតមកដល់បច្ចុប្បន្ននេះ ដើម្បីឆ្លើយតបការទប់ស្កាត់ការឆ្លងរាលដាលមេរោគអេដស៍ ជំងឺអេដស៍ និងដើម្បីឈានទៅរកការលុបបំបាត់ចោលនូវការរើសអើងនៅក្នុងសហគមន៍មានដូចតទៅ :

- បានធ្វើសកម្មភាពចុះសួរសុខទុក្ខកុមារកំព្រា ដោយសារជម្ងឺអេដស៍ និងកុមារងាយរងគ្រោះ
- បានបញ្ជូនកុមារកំព្រាដែលមិនរៀនឱ្យបានចូលរៀននៅសាលារដ្ឋ
- តាមដានការសិក្សារបស់កុមារ នៅរាល់មួយខែម្តងជាប្រចាំ
- ចុះសួរសុខទុក្ខអ្នកជំងឺអេដស៍នៅតាមផ្ទះជារៀងរាល់សប្តាហ៍
- ចែកស្បៀង គ្រឿងឧបភោគ បរិភោគដល់កុមារកំព្រាជារៀងរាល់ខែ
- ចែកសំលៀកបំពាក់ និងសម្ភារៈសិក្សាជារៀងរាល់ឆ្នាំ និងប្រចាំខែផងដែរ
- ប្រជុំកុមារ និងអាណាព្យាបាលកុមារ មានអ្នកផ្ទុកជំងឺអេដស៍ និងអ្នកជម្ងឺអេដស៍រាល់មួយខែម្តង
- បញ្ជូនកុមារ និងអាណាព្យាបាលកុមារ អ្នកជំងឺអេដស៍ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យជាប្រចាំខែ (ដោយបានថវិកាពីក្រុមជួយខ្លួនឯងខ្លះ និងបានទទួលការឧបត្ថម្ភផ្នែកសេវាដឹកជញ្ជូនពីអង្គការអូស្ត្រាលីសង្គ្រោះកុមារ)
- កម្មវិធីបានចែកកង់ដល់កុមារកំព្រា និងកុមារងាយរងគ្រោះដោយសារអេដស៍ បានចំនួន ៣០គ្រឿង ដោយគិតចាប់តាំងពីឆ្នាំ២០០៥ មកដល់ឆ្នាំ២០០៧នេះ បានទទួលថវិកាឧបត្ថម្ភពីអង្គការ និងក្រុមជួយខ្លួនឯង ។

(១) របាយការណ៍របស់អង្គការពុទ្ធមណ្ឌលសុខុមាលភាពកុមារស្ត្រី ពុទ្ធសាសនា និងការអប់រំសីលធម៌

- បានជួយថវិកាមួយចំណែកសម្រាប់ធ្វើបុណ្យ និងជួយសម្រួលដល់ការបូជាសព ដោយមានការអនុគ្រោះតម្លៃពីព្រះចៅអធិការវត្ត និងគណៈកម្មការសម្រាប់អ្នកជំងឺអេដស៍ ចំពោះកុមារ ឬអាណាព្យាបាលដែលបានស្លាប់។
- បាននិងបន្តធ្វើកិច្ចការនេះតទៅទៀត។ ទិសដៅសំខាន់នៅឆ្នាំ២០០៧ ក្រុមការងារវត្តច្បារអំពៅ ក៏ដូចជាអង្គការអូស្ត្រាលីដែរ ជំរុញឱ្យគ្រួសារអ្នកទទួលផល ខិតខំរកមុខរបរខ្នាតតូចដើម្បីធ្វើការលក់ដូររកប្រាក់ចំណូលដោយខ្លួនឯង ហើយអង្គការអូស្ត្រាលីនឹងផ្ដល់ថវិកាឱ្យខ្ចី ហើយឱ្យសងវិលសដោយមិនគិតការប្រាក់ដោយចង់ឱ្យគ្រួសារគាត់មានមុខរបរអាចរកប្រាក់ចំណូលទ្រទ្រង់ជីវភាពក្រុមគ្រួសារគាត់បានធូរធារផងដែរ
- អង្គការយើងបានផ្ដល់ថវិកាឱ្យខ្ចីបានចំនួន២៧គ្រួសារហើយ និងជួយដល់គ្រួសារបន្តបន្ទាប់ទៀត។

ជាបញ្ចប់ ព្រះអង្គក៏បានអំពាវនាវដល់សប្បុរសជន ប្រជាពលរដ្ឋទាំងអស់ មេត្តាជួយផ្ដល់កម្លាំងចិត្ត ប្រាជ្ញាស្មារតី ជួយឧបត្ថម្ភដល់ពួកគាត់ ទាំងសម្ភារៈ និងថវិកាតាមសទ្ធាជ្រះថ្លា ដោយមានការអនុគ្រោះ សូមកុំឱ្យមានការប្រកាន់ឋានៈ ខ្ពស់ទាបមានក្រឡើយ ហើយបែរមកនិយាយរាក់ទាក់ជាមួយពួកគេ ប្រកបដោយភាពស្និទ្ធស្នាលដូចធម្មតា ធ្វើដូចនេះទើបសហគមន៍យើងមិនមានការរើសអើងតទៅទៀត[២] ។

## ២.៤ អ្នកជម្ងឺក្នុងមន្ទីរពេទ្យ

ព្រះសង្ឃតែងចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមមន្ទីរពេទ្យ ពិសេសគឺអ្នកជំងឺដែលអស់ក្ដីសង្ឃឹមក្នុងជីវិត (អេដស៍) ដើម្បីជាការលើកទឹកចិត្តដល់ពួកគេ។ ព្រះអង្គបានពន្យល់ ណែនាំនូវហេតុផលផ្សេងៗដែលបានកើតមាន (អប់រំផ្លូវចិត្ត) កុំឱ្យពួកគេមានគំនិតគិតខ្លីដោយប្រការណាមួយ។ ព្រះសង្ឃគឺជាសរណៈដ៏ប្រសើរដែលប្រជាពលរដ្ឋខ្មែរយើងតែងគោរពបូជាធ្វើឱ្យពួកគេមានជំនឿជឿជាក់ និងមានក្ដីសង្ឃឹមក្នុងជីវិត ហើយព្រះអង្គក៏បានចែកអំណោយខ្លះៗដល់ពួកគេផងដែរ។

## ២.៥ អប់រំទណ្ឌិត

ក្រោមទ្រឹស្ដីនៃការអប់រំរបស់ព្រះពុទ្ធសាសនា ព្រះសង្ឃតែងមានទឹកព្រះទ័យប្រកបដោយ មេត្តា ករុណាជានិច្ច មិនថាអ្នកក្រីក្រ ទុគ៌ត អនាថា ឬអ្នកជម្ងឺនោះទេ សូម្បីនៅមន្ទីរឃុំឃាំង (គុក) ដែលជាកន្លែងសម្រាប់ដាក់ទោសទណ្ឌ អ្នកប្រព្រឹត្តល្មើសច្បាប់ផ្សេងៗ ក៏ព្រះអង្គបានសុំការអនុញ្ញាតពីឆ្មាំគុកចូលទៅសួរសុខទុក្ខ ទាំងយកអំណោយខ្លះៗទៅចែកដល់ពួកគេ និងធ្វើការអប់រំពន្យល់ហេតុផល កុំឱ្យពួកគេបង្កនូវភាពវឹកវរក្នុងសង្គម កុំឱ្យមានការចងគំនុំគុំគួនគ្នា ឱ្យពួកគេចេះកែខ្លួន ធ្វើខ្លួនឱ្យក្លាយជាពលរដ្ឋល្អ ប្រព្រឹត្តសុចរិតធម៌ត្រឹមត្រូវ ឱ្យចេះគិតពីអនាគតខ្លួន ប្រពន្ធ កូនចៅ និងក្រុមគ្រួសារ នៅពេលត្រឡប់មករស់នៅក្នុងសង្គមវិញ (ចេញពីពន្ធនាគារ) ។

(នៅមានត)

អនុបណ្ឌិត គួយ សូគាន

(២) សុន្ទរកថា (ព្រះសង្ឃវត្តច្បារអំពៅ) ស្ដីពីការទប់ស្កាត់ការឆ្លងរាលដាលមេរោគអេដស៍ ជម្ងឺអេដស៍ ការកាត់បន្ថយការរើសអើងនៅក្នុងសហគមន៍ឆ្នាំ២០០៧

# ស្គាល់កម្ពស់តាមប្រវែងឆ្អឹង

ស្ត្រីអ្នកវិទ្យាសាស្ត្រម្នាក់បានបង្ហាញនិស្សិតមួយក្រុមនូវឆ្អឹងស្មងជើងធំមួយកំណាត់ (Tibia bone) នៃសាកសពក្មេងប្រុសម្នាក់អាយុដប់ឆ្នាំ ដែលបានរស់នៅក្នុងប្រទេសបារាំង កាលពី ៤00ឆ្នាំមុន។

អ្នកស្រីបានបង្ហាញពីរូបមន្តដែលក្រុមអ្នកវិទ្យាសាស្ត្របានគណនាប្រវែងកម្ពស់របស់កុមារនោះ តាមរយៈឆ្អឹងស្មងជើងធំមួយកំណាត់នោះ និងឆ្អឹងផ្សេងទៀត។

ដោយដឹងថា ឆ្អឹងស្មងជើងធំរបស់កុមារនោះប្រវែង ២៤cm រូបមន្តសម្រាប់គណនារកប្រវែងកំពស់របស់កុមារនោះ គឺ :

| |
|---|
| ប្រវែងកម្ពស់ = (៣,៣៥ x ប្រវែងឆ្អឹងស្មងជើងធំ) + ៤៤ |

កម្ពស់កុមារនោះ (cm) = (3,35 x 24) + 44
= 80,4 + 44
= 124,4

=> កុមារនោះកម្ពស់ 124cm ឬ 1,24m




**អនុវត្តន៍** : តើយើងមានកម្ពស់ប្រវែងប៉ុន្មាន?

១-ចូរអ្នកវាស់ឆ្អឹងបីប្រភេទនៃមិត្តរបស់អ្នក និងឱ្យមិត្តនោះវាស់ឆ្អឹងទាំងបីប្រភេទនេះរបស់អ្នកវិញ ដាក់ក្នុងតារាងខាងក្រោម :

| ប្រវែងឆ្អឹង (គិតជាសង់ទីម៉ែត្រ) | | | កំណត់សម្គាល់ |
|---|---|---|---|
| ប្រភេទឆ្អឹង | របស់អ្នក | របស់មិត្តអ្នក | គេវាស់ប្រវែងឆ្អឹងទាំងបីប្រភេទនេះតាមអវៈយវៈ (ដៃ ជើង) ជាក់ស្តែងរបស់មនុស្សពីខាងក្រៅ។ |
| ឆ្អឹងស្មងជើងធំ (ពីជង្គង់ទៅកជើង) | | | |
| ឆ្អឹងដើមដៃ (ពីស្មាទៅកែងដៃ) | | | |
| ឆ្អឹងកំភួនដៃ (ពីកែងដៃទៅកដៃ) | | | |

២-អនុវត្តរូបមន្តខាងក្រោមនេះ ដើម្បីរកប្រវែងកម្ពស់របស់អ្នក និងមិត្តអ្នកតាមរយៈប្រវែងឆ្អឹងដែលកត់ត្រាបានពីលំហាត់លេខ ១។

៣- ប្រៀបធៀបប្រវែងកម្ពស់របស់អ្នក ឬរបស់មិត្តអ្នកតាមប្រវែងឆ្អឹងនីមួយៗដែលរកឃើញក្នុងលំហាត់លេខ ២។

**រូបមន្តគណនាប្រវែងកម្ពស់កុមារ (គិតជា ស.ម)**
**ពីអាយុ១០ឆ្នាំ ដល់ ១៥ឆ្នាំ**

**កុមារា**

កម្ពស់ = (៣,៣៩ x ប្រវែងឆ្អឹងស្មងជើងធំ) + ៤៤
= (៤,៩១ x ប្រវែងឆ្អឹងដើមដៃ) + ១៦,៥
= (៥,៥៦ x ប្រវែងឆ្អឹងកំភួនដៃ) + ៣០,៥

**កុមារី**

កម្ពស់ = (២,៩ x ប្រវែងឆ្អឹងស្មងជើងធំ) + ៥៨,៧
= (៥,៨៥ x ប្រវែងឆ្អឹងកំភួនដៃ) + ៣៥,៣
= (៤,១១ x ប្រវែងឆ្អឹងដើមដៃ) + ៣៦,៩

ដើម្បីចៀសវាងលំអៀងឆ្ងាយពេក រង្វាស់ប្រវែងត្រូវគិតជា cm ៕

លោក ខៀវ ស៊ន
នាយកសាលាប.ឋ.ស ភូមិវាល
ស្រុកជើងព្រៃ ខេត្តកំពង់ចាម

**ខន្តីប្រធាន ប្រសើរលើសទាន**
**ធំក្រៃគន្លង ជាមេអស់ផល**
**អស់គូសលផង គម្របចិត្តចង**
**បានសីលខន្តីៗ**

សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក
គណៈមហានិយចន្ទរត្តោ ជួន ណាត

ប្រភព : Math in My World, Mc Grow-Hill, New York, USA.



# ចិត្តវិទ្យាអប់រំ

## ការជួយកុមារក្នុងការរៀនសូត្រ

### ការស្ថាបនាខួរក្បាលរបស់កុមារ

ខួរក្បាលកុមារបានរីកលូតលាស់ចាប់តាំងពីមុនពេលកើត។ ដោយសារទារកនៅក្នុងផ្ទៃម្តាយលូតលាស់ សែន កោសិកាខួរក្បាលក៏លូតលាស់ដែរ។ លានទីមួយៗនៃខួរក្បាលក្លាយជាកន្លែងដែលមានការរៀបចំល្អ ដើម្បីត្រៀមលក្ខណៈទទួលព័ត៌មាន។ ក្រោយពេលកើត ទារកស្តាប់ឮសំឡេងដែលបណ្តាលឱ្យកោសិកាប្រសាទ ហៅណឺរ៉ូន ភ្ជាប់ទំនាក់ទំនងជាមួយកោសិកាប្រសាទដទៃទៀត។ ទារកមើលឃើញមុខឪពុកម្តាយ ហើយបន្ទាប់មកណឺរ៉ូនពីរទៀតត្រូវបានភ្ជាប់ទំនាក់ទំនងជាមួយគ្នា។ ខួរក្បាលរបស់ទារករីកលូតលាស់រហ័សណាស់។ ដង់ស៊ីតេខួរក្បាលកើន។ មានការធ្វើពិសោធន៍ជាច្រើនបានរួមចំណែកក្នុងការយល់ដឹងអំពីការលូតលាស់របស់ខួរក្បាល។

### ការចូលរួមរបស់ឪពុកម្តាយ

ព័ត៌មានថ្មីៗអំពីការលូតលាស់ខួរក្បាលបានធ្វើឱ្យឪពុកម្តាយភ្ញាក់ផ្អើល។ របកគំហើញទាំងនោះបានឱ្យដឹងថា ឪពុកម្តាយមានឥទ្ធិពលយ៉ាងធំធេងទៅលើការលូតលាស់ខួរក្បាលរបស់កូន។

### ពេលវេលាល្អបំផុតដើម្បីអភិវឌ្ឍ

តាមការស្រាវជ្រាវបានឱ្យដឹងថា ខួរក្បាលមានសមត្ថភាពកាន់តែប្រសើរ ដើម្បីទទួលបាននូវភាពប៉ិនប្រសប់ក្នុងរយៈពេលកំណត់មួយ។ ឪពុកម្តាយ និងអ្នកថែទាំកុមារអាចចាប់យកគុណប្រយោជន៍នៃឱកាសប្រសើរបំផុតនេះឱ្យបាន។ ឧទាហរណ៍ : ភ្នែក (ការមើលឃើញ) ត្រូវលូតលាស់នៅវ័យទារក ឬមួយនៅរក្សាទុកភាពខ្សោយរបស់វាពេញមួយជីវិត។ ពេលវេលាប្រសើរបំផុតសម្រាប់ការយល់ដឹងអំពីបំណិនចលករមូលដ្ឋានត្រូវប្រព្រឹត្តទៅចាប់តាំងពីកំណើតរហូតដល់អាយុ ៥ឆ្នាំ។

លានខួរក្បាលដែលយល់ដឹងអំពីវិធានភាសា បានបើកទូលាយដើម្បីទទួលរំញោចរហូតដល់អាយុប្រហែល ៦ឆ្នាំ។ លានខួរក្បាលសម្រាប់ការយល់ដឹងពាក្យពេចន៍ បើកទូលាយរហូតអស់មួយជីវិត៕

លោក ប៉ែន ស៊ីមហួន

# ពហុបញ្ញា

ការស្រាវជ្រាវថ្មីៗធ្វើដោយលោក ហូវ៉ាដ ហ្កាដន័រ (Howard Gardner) សាស្ត្រាចារ្យនៅសាកលវិទ្យាល័យសហរដ្ឋអាមេរិក បានឱ្យដឹងថា ខួរក្បាលមនុស្សមានលានប្រាជ្ញា ៨ គឺលានភាសា លានតក្ក-គណិតវិទ្យា លានលំហ លានកាយ-ចលនា លានតន្ត្រី លានអន្តរបុគ្គល (រវាងបុគ្គល និងបុគ្គល) លានអន្តោបុគ្គល (ខាងក្នុងខ្លួនបុគ្គល) លានធម្មជាតិនិយម។

ទ្រឹស្តីពហុបញ្ញាបានឱ្យដឹងទៀតថា មនុស្សគ្រប់គ្នាមានលានប្រាជ្ញាដូចគ្នា ប៉ុន្តែមានកម្រិតប្រាជ្ញាខ្លាំង ឬខ្សោយខុសៗគ្នា។ ឧទាហរណ៍ : កុមារម្នាក់អាចមានប្រាជ្ញាតន្ត្រីខ្លាំង ក៏ប៉ុន្តែខ្សោយផ្នែកភាសា។ ដូច្នេះឪពុកម្តាយគប្បីពិចារណាឱ្យច្បាស់លាស់ ដើម្បីវាយតម្លៃចំណុចខ្លាំងរបស់កូនម្នាក់ៗ ត្រូវជួយកូនឱ្យអភិវឌ្ឍ និងប្រើប្រាស់ចំណុចខ្លាំងនេះឱ្យមានប្រយោជន៍។

## បង្កើនបំណិនគំនិត

ការលូតលាស់សតិបញ្ញា ជាលំនាំស្ថាបនាមួយ។ កាលណាកុមារមានបទពិសោធន៍កាន់តែច្រើន នោះកុមារប្រើបំណិនគំនិតកាន់តែច្រើនដែរ។ បើកុមារអនុវត្តគិតកាន់តែច្រើន នោះកុមារកាន់តែយល់បទពិសោធន៍ថ្មីៗថែមទៀត។ ឪពុកម្តាយអាចជួយពង្រឹងបំណិនគំនិតរបស់កូន ដោយផ្តល់ឱកាសឱ្យកូនអនុវត្តបំណិននោះ។

## លំនឹក

លំនឹកត្រូវបានពង្រឹងឱ្យរឹងមាំ កាលណាកុមារផ្សារភ្ជាប់ពាក្យពេចន៍ និងបញ្ញត្តិទៅនឹងពិសោធន៍។ នៅពេលដែលឪពុកម្តាយផ្តល់ព័ត៌មានមុនព្រឹត្តិការណ៍ រូបភាពត្រូវបានរំលឹក (នឹកឃើញឡើងវិញ) កាន់តែច្បាស់។ បន្ទាប់មក ពិសោធន៍ណាដែលបានធ្វើឱ្យចាប់អារម្មណ៍ និងអាចយល់បាននោះ ធ្វើឱ្យនឹកឃើញបានល្អជាង។ ឪពុកម្តាយអាចជួយកូន (កូនធំបន្តិចហើយ) អភិវឌ្ឍយុទ្ធសាស្ត្រធ្វើលំនឹកឱ្យកាន់តែល្អប្រសើរឡើង ដូចជាការរៀបចំវត្ថុជាកំរង ជាក្រុមដែលជួយកុមារឱ្យនឹកឃើញវត្ថុទាំងនោះឡើងវិញ ដោយផ្អែកលើគុណភាពរូមរបស់វា ដូចជាពណ៌ដូចគ្នាជាដើម។

## ការចង់ចេះចង់ដឹង

ការចង់ចេះចង់ដឹងជំរុញចិត្តចង់របស់កុមារឱ្យយល់ដឹងអំពីពិភពជុំវិញ។ ដើម្បីធ្វើឱ្យការចង់ចេះចង់ដឹងដំណើរការសកម្ម ឪពុកម្តាយអាច :

### ១-លើកទឹកចិត្តកូនឱ្យសួរសំណួរ

ចម្លើយរបស់ឪពុកម្តាយទៅនឹងសំណួរ "ហេតុអ្វី?" របស់កូន បានលើកទឹកចិត្តកូនឱ្យមានការចង់ចេះចង់ដឹង។ និយាយថា "ខ្ញុំមិនដឹងទេ ក៏ប៉ុន្តែនឹងខិតខំព្យាយាមរកឱ្យឃើញ"។ ចូរបើកទ្វារចំហសម្រាប់ការរុករកផ្សេងៗទៀត។

(នៅមានត)

លោក ប៉េង ស៊ីមហួច

# វិបត្តិដំណេក និងផលប៉ះពាល់ នៅលើការរៀនសូត្ររបស់សិស្ស (ត)

## ចំពោះជំទង់

ហាងធំៗ កុំព្យូទ័រ ទូរទស្សន៍ កិច្ចការគ្រូដាក់ឱ្យធ្វើនៅផ្ទះ និងការផ្លាស់ប្តូរបែបបទរស់នៅក្នុងគ្រួសារ ទាំងអស់នេះ បានធ្វើឱ្យក្មេងជំទង់ដេកពេលយប់ពុំសូវលក់ ហើយកង្វះខាតដំណេករបស់ពួកគេនៅតែមានជាប់ជាបន្តបន្ទាប់ដែលអាចបណ្តាលឱ្យមានបញ្ហាមិនល្អដល់ពួកគេ។ ឧទាហរណ៍ : មានគ្រោះថ្នាក់ចរាចរណ៍បានកើតមានឡើងជាច្រើនករណីដែលបណ្តាលមកពីក្មេងជំទង់ និងយុវជនមានការងុយដេក។ នៅឆ្នាំ១៩៩៧ វិទ្យាស្ថានជាតិនៃសុខភាព នៅសហរដ្ឋអាមេរិកបានកោះប្រជុំក្រុមការងារផ្នែកវិទ្យាសាស្ត្រមួយក្រុម ដើម្បីពិនិត្យបញ្ហានៃការងងុយដេករបស់ក្មេងជំទង់។ លទ្ធផលនៃការស្រាវជ្រាវរបស់ក្រុមនេះ និងក្រុមផ្សេងទៀត ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ២០០០ នៅក្នុងរបាយការណ៍មួយដែលមានឈ្មោះថា "តម្រូវការដេករបស់ក្មេងជំទង់ និងលំនាំរបស់វា ដោយមូលនិធិជាតិនៃដំណេក (National Sleep Foundation: NSF)។

## តម្រូវការដេករបស់ក្មេងជំទង់ និងលំនាំនៃការដេក

### កំរិតពេលម៉ោង និងលំនាំនៃការដេក

តាមរបាយការណ៍របស់ NSF បានបង្ហាញឱ្យឃើញថា ពេលដេកជាមធ្យមរបស់ក្មេងជំទង់នៅអាយុ ១៣ឆ្នាំ ក្នុងសប្តាហ៍សិក្សា គឺ ៧ម៉ោង និង៤២នាទី ហើយថយចុះមក ៧ម៉ោង សម្រាប់អ្នកដែលមានអាយុ១៩ឆ្នាំ។ នៅក្នុងរបាយការណ៍នោះដែរ គេបានឱ្យដឹងទៀតថា គឺមានជំទង់តែ ១៥% ប៉ុណ្ណោះដែលដេក ៨ម៉ោងកន្លះ ឬលើសពីនេះនៅពេលយប់នៃសប្តាហ៍សិក្សា ហើយមានចំនួន ២៦% ដេកបាន ៦ម៉ោងកន្លះ ឬតិចជាងនេះ នៅពេលយប់នៃសប្តាហ៍សិក្សានីមួយៗ។ តារាងនៃការដេកនៅពេលឈប់ចុងសប្តាហ៍មានភាពខុសគ្នាពីកាលវិភាគនៃការដេកក្នុងសប្តាហ៍ធ្វើការ។ ជំទង់ដែលជាមុខសញ្ញានៃការសិក្សាស្រាវជ្រាវនេះបានដេកនៅថ្ងៃឈប់ចុងសប្តាហ៍ លើសប្រហែលជា ១ម៉ោងកន្លះទៅ ២ម៉ោងពីថ្ងៃធម្មតា។

### វិបត្តិនៃដំណេកយឺតយ៉ាវ

ដោយសារក្មេងជំទង់ចូលដេកយឺតយ៉ាវនៅពេលយប់ (ជិតពាក់កណ្តាលអធ្រាត្រ) ពួកគេត្រូវការពន្យារដំណេករបស់គេរហូតដល់ម៉ោង ៩ព្រឹក ដើម្បីបង្គ្រប់ម៉ោងដេកឱ្យបានគ្រប់ ៩ម៉ោង។ ប៉ុន្តែនៅក្នុងសប្តាហ៍ធ្វើការវិញ ពួកគេត្រូវក្រោកពីដំណេកប្រហែលជាម៉ោង ៦ព្រឹក ពីព្រោះពួកគេត្រូវទៅដល់សាលានៅម៉ោង ៧ព្រឹក (តាមម៉ោងកំណត់នៅកម្ពុជាយើង)។ ដូច្នេះ សិស្សកម្រិតមធ្យមសិក្សាជាច្រើននាក់ត្រូវតែបង្ខំចិត្តក្រោកពីដំណេក បន្ទាប់ពីគេបានដេក ៦ម៉ោងកន្លះ ទៅ ៧ ម៉ោង រួចហើយក៏ដោយ ក៏មានផ្ទុកជាតិម៉េឡាតូនីនក្នុងខ្លួននៅឡើយ។ នៅពេលពួកគេទៅដល់សាលា ពួកគេនៅតែងុយដេក ហើយជារឿយៗពួកគេច្រើនតែដេកលក់ក្នុងថ្នាក់នៅក្នុងម៉ោងរៀនទៀតផង។

ភាពមិនត្រូវគ្នារវាងបំលាស់ប្តូរដំណាក់នៃការដេករបស់ជំទង់ និងពេលវេលាដែលយើងសំណូមពរឱ្យពួកគេទៅសាលា បាននាំឱ្យកើតជាដំណាក់ត្រាំត្រែងមួយដែលគេហៅថា : ដំណាក់វិបត្តិនៃដំណេកយឺតយ៉ាវ (Delayed Sleep

Phase Disorder =DSPD) ។

ទោះជាយ៉ាងនេះក៏ដោយ ក៏វិបត្តិនេះអាចមានផលប៉ះពាល់ធ្ងន់ធ្ងរធ្វើឱ្យខូចផលប្រយោជន៍ផងដែរ គឺ :

- ធ្វើឱ្យមានការងោកងុយ និងការហត់នឿយដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ជាពិសេសការបុកគ្នា ឬការ ប៉ះទង្គិចគ្នានៃយានយន្ត
- ធ្វើឱ្យថមថយភាពម្ចាស់ការ ដើម្បីត្រួតពិនិត្យចិត្តរំភើបដែលនាំឱ្យមានការឈ្លោះប្រកែកគ្នា ការខឹងក្រោធ និងការធ្លាក់ទឹកចិត្តជាដើម
- ធ្វើឱ្យកើតមានបញ្ហាក្នុងការរៀនសូត្រចំពោះសិស្សកំរិតមធ្យមសិក្សាដែលបានពិន្ទុទាប (ដោយសារពួកគេដេកពុំគ្រប់គ្រាន់) ជាងសិស្សដែលបានដេកគ្រប់គ្រាន់
- អាចបណ្ដាលឱ្យមានវិបត្តិនៃការថមថយបម្រុងប្រយ័ត្ន
- បង្កើនការប្រើប្រាស់សារធាតុភ្លោច ដូចជាជាតិកាហ្វេអ៊ីន ជាតិនីកូទីន និងស្រាជាដើម ។

## **វិបត្តិដំណេក**

វិបត្តិដំណេកដែលច្រើនតែជួបប្រទះគឺការដេកពុំលក់ (Insomnia) ការថប់ដង្ហើមក្នុងពេលដេក (Sleep apea) ការរសាប់រសល់ក្នុងជើង (restless legs syndrome) និងការងុយដេកទ្រាំមិនបាន (narcolepsy) ។

### ក_ការដេកពុំលក់

មានអ្នកខ្លះទទួលរងនូវការដេកពុំលក់ដោយពេល ។ ខ្លះទៀតដេកពុំលក់ត្រាំត្រែង (ចង់និយាយថាពួកគេដេកពុំលក់រាល់ពេលយប់) ។

ការដេកពុំលក់ត្រាំត្រែងនេះកើនទៅតាមអាយុ ហើយក៏អាចបង្កជាដើមហេតុនៃវិបល្លាស ឬវិបត្តិផ្នែកវិជ្ជសាស្ត្រផងដែរ ។ ចំពោះការដេកពុំលក់ត្រាំត្រែងនេះ អ្នកសិក្សាស្រាវជ្រាវកំពុងធ្វើពិសោធន៍ជាមួយនឹងវិធិព្យាបាលងាយៗ និងវិធីផ្សេងទៀត ដើម្បីកែតំរូវវដ្ត "ដេក-ភ្ញាក់" របស់រាងកាយ ។

### ប្រសិនបើលោកអ្នកដេកពុំលក់ តើត្រូវធ្វើដូចម្ដេច?

ការដេកមិនលក់ម្ដងម្កាលវាជាការរំខានមួយដែរ ប៉ុន្ដែវាស្ថិតនៅកំរិតស្រាលនៅឡើយ ។ ប្រសិនបើជាការដេកមិនលក់ត្រាំត្រែងវិញ (ដេកមិនលក់រាល់យប់)នោះ វានឹងក្លាយទៅជាវិបត្តិដំណេកធ្ងន់ធ្ងរ ។ លោកអ្នកគប្បីអញ្ជើញទៅជួបគ្រូពេទ្យកុំបីខាន ។

ប្រសិនបើលោកអ្នកដេកមិនលក់ម្ដងម្កាល ដែលជាការដេកមិនលក់កំរិតស្រាលនៅឡើយនោះ លោកអ្នកអាចសាកល្បងដោះស្រាយដោយខ្លួនឯងបានដែរតាមបទពិសោធន៍របស់លោក ហួរី និងលោករ៉ូសិនប៊ែរ (Hauri, 1982, and Rosenberg, 1990) ដូចខាងក្រោម :

១-ចូលដេកនៅពេលដែលលោកអ្នកងុយដេក ។ បើមិនទាន់ងុយទេ ចូរកុំទាន់ចូលដេក ។ បើលោកអ្នកមានអារម្មណ៍ថា យប់នេះប្រហែលជាដេកមិនលក់ទេនោះ លោកអ្នកគប្បីក្រោកងើបចេញពីគ្រែ រួចហើយរកអ្វីធ្វើបន្តិចបន្តួច ដូចជាជូតផ្ទះ ឬអានកាសែត ឬអានសៀវភៅ ឬមើលទូរទស្សន៍ ឬស្ដាប់វិទ្យុជាដើម រួចសឹមវិលមកចូលដេកវិញនៅពេលដែលលោកអ្នកចាប់ផ្ដើមងងុយដេកហើយនោះ ។

២-ខិតខំបង្កើតទំលាប់ក្រោកពីដេកទៀងពេលរៀងរាល់ថ្ងៃតាមពេលម៉ោងកំណត់ (វាជាការលំបាកដែរ ដើម្បីដេកទៀងពេល ប្រសិនបើលោកអ្នកក្រោកពីដំណេកមិនទៀងពេលដែរនោះ)។

៣-ចៀសវាងកុំទទួលទានរបស់ណាដែលមានជាតិកាហ្វេអ៊ីន ឬមានជាតិនីកូទីននៅពេលល្ងាច។

៤-ចៀសវាងការប្រើប្រាស់តាមទំលាប់នូវស្រា ឬថ្នាំជំនួយដំណេក ដើម្បីជួយឱ្យដេកលក់។

៥-បន្ទប់ដេកត្រូវស្ងប់ស្ងាត់ និងមានភាពត្រជាក់ល្អ (ចង់និយាយថាមិនក្តៅស្អុះស្អាប់ និងមិនមានសំឡេងរំខាន)។

៦-ហាត់ប្រាណឱ្យបានទៀងទាត់រៀងរាល់ថ្ងៃ។

**ខ_ការថប់ដង្ហើមក្នុងដំណេក**

វិបត្តិនេះពុំសូវកើតមានចំពោះក្មេងៗទេ។ នេះគឺជាលក្ខខណ្ឌមួយដែលបណ្តាលឱ្យមានការថប់ដង្ហើមនៅពេលដេក។ វាអាចបណ្តាលមកពីការបាត់បង់ ភាពកន្ត្រាក់សាច់ដុំតាមផ្នែកនៃរាងកាយ នៅពេលមានអាយុច្រើន ឬមកពីដំណើរការមិនល្អនៃហ៊ីរ៉ូន ដែលបញ្ជាដង្ហើមនៅពេលដេក។

បំពង់ខ្យល់ដង្ហើមហាក់ដូចជារួមតូចធ្វើឱ្យការផ្តល់អុកស៊ីសែនទៅឱ្យសរីរាង្គក្នុងខ្លួនមិនគ្រប់គ្រាន់ (បន្ថយបរិមាណអុកស៊ីសែន)។ នៅពេលកម្រិតអុកស៊ីសែនក្នុងឈាមចុះទាបខួរក្បាលក៏ដាស់សាមីជនឱ្យភ្ញាក់ឡើង ដើម្បីបើកបំពង់ខ្យល់ដង្ហើមឱ្យធំ។ ដោយសារសាមីជនដេកលក់ទៅវិញនោះ បំពង់ខ្យល់ដង្ហើមក៏រួមតូចទៅវិញជាថ្មីទៀត។ ក្នុងមួយយប់ៗ វាអាចកើតមានករណីរបៀបនេះរាប់រយដងដដែលៗ ធ្វើឱ្យសាមីជន រងើរងើ និងឆាប់ខឹងនៅពេលភ្ញាក់ពីដំណេកនាពេលព្រឹកព្រលឹម។ វិបត្តិនេះអាចព្យាបាលតាមការបញ្ចុះទម្ងន់ ឬដេកផ្អៀងមួយចំហៀងខ្លួន។

**គ_ការរសាប់រសល់ចាក់ឆៀបៗក្នុងជើង**

គឺជាវិបត្តិសេនេទិច ដែលកើតមានចំពោះអ្នកដែលមានអាយុច្រើន និងចំពោះក្មេងៗខ្លះដែរ។ វិបត្តិនេះបង្កឱ្យមានការរសាប់រសល់ចាក់ឆៀបៗក្នុងជើង និងបាតជើង ហើយធ្វើឱ្យកំរើកជើងចុះឡើងៗ ដើម្បីរកភាពធូរស្បើយ។ ចលនាកំរើកជើងចុះឡើងៗនេះធ្វើឱ្យដេកពុំលក់នៅពេលយប់។

**ឃ_ការងុយដេកទ្រាំមិនបាន (ឬការចេះតែងុយដេក)**

វិបត្តិដំណេកប្រភេទនេះកើតមានចំពោះជនជាតិអាមេរិកាំងប្រមាណ ២៥០ ០០០នាក់។ វាធ្វើឱ្យងុយដេកទ្រាំមិនបាននៅពេលថ្ងៃតាមពេលម៉ោងខុសៗគ្នា បើទោះបីជាពួកគេបានដេកឆ្អែតពេលយប់ក៏ដោយ។ រយៈពេលដេកនេះមាន ចាប់តាំងពីរាប់សិបវិនាទី ទៅ ៣០នាទី។ វាច្រើនកើតមានចំពោះជំទង់។ តាមធម្មតាវាមានលក្ខណៈតពូជ ក៏ប៉ុន្តែវាអាចកើតមានពីការរងរបួសក្បាល ឬពីជំងឺសរសៃប្រសាទផងដែរ។

(នៅមានត)

លោក ម៉េង ស៊ីមហួច




# ការអភិវឌ្ឍជំនាញវិស្វកម្ម (ត)

## តួនាទីជំនាញវិស្វកម្មក្នុងវិស័យពាណិជ្ជកម្ម

និន្នាការសហស្សវត្សរ៍ថ្មីបានចាត់ទុកវិស័យសេវាកម្មជាឧស្សាហកម្មពេញនិយម ដែលមុននេះវិស័យសេដ្ឋកិច្ចមានមូលដ្ឋានសំខាន់លើឧស្សាហកម្មទ្រព្យសម្ភារៈ និងទេសចរណ៍។ ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) វិស័យពាណិជ្ជកម្មបានធ្វើសមាហរណកម្មក្នុងតំបន់ និងធ្វើសកលភាវូបនីយកម្ម ហើយនាំទៅដល់ការព្រមព្រៀងលើគម្រោងការសេវាកម្មអាស៊ាន (ASEAN Framework Agreement on Service : AFAS)[១] និងកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (General Agreement on Trade in Services : GATS)[២] ។

### អង្គការពាណិជ្ជកម្មពិភពលោក និងទីសាលគាព

អង្គការពាណិជ្ជកម្មពិភពលោក WTO (World Trade Organization) ត្រូវបានបង្កើតឡើងជាស្ថាប័នបង្កើតច្បាប់ និងជាស្ថាប័នអនុវត្តច្បាប់ក៏រិតអន្តរជាតិខាងវិស័យពាណិជ្ជកម្មដែល :

- ការពារប្រព័ន្ធពាណិជ្ជកម្មពហុភាគីតាមរយៈការពិគ្រោះច្បាប់ពហុភាគី
- ជាស្ថាប័នអន្តររដ្ឋាភិបាលសម្រាប់ត្រួតពិនិត្យការអនុវត្ត និងដំណោះស្រាយរាល់ទំនាស់ក្នុងវិស័យពាណិជ្ជកម្ម
- ជាវេទិកាជជែក និងចរចាដោះស្រាយបញ្ហាក្នុងវិស័យពាណិជ្ជកម្ម
- ជាកិច្ចព្រមព្រៀងស្តីពីច្បាប់ វិន័យ យុត្តិវិធី និងការប្រព្រឹត្តទៅខាងវិស័យផលិតកម្ម សេវាកម្ម ច្បាប់កម្មសិទ្ធិបញ្ញា និងការដោះស្រាយជម្លោះ ។

គោលការណ៍ចម្បងរបស់ WTO មាន :

- ការមិនប្រកាន់ពូជសាសន៍ សាសនាក្នុងទំនាក់ទំនងពាណិជ្ជកម្ម
- ប្រព្រឹត្តកម្មជាតិ (National Treatment) ដោយមិនប្រកាន់ផលិតផល និងសេវាកម្មក្នុងស្រុក ឬក្រៅស្រុក

(១) របាយការណ៍សិក្ខាសាលា : Productive force of development, EIC-2001, Eng. Choo Kok Beng, page 20

(២) URUGUATY ROUND AGREEMENT WTO Secretariat Geneva (website : www.wto.org)

- ផ្ដល់សម្បទានឱ្យគ្នានូវការព្យាករណ៍
- ការប្រកួតប្រជែងដោយយុត្តិធម៌
- ប្រព្រឹត្តកម្មពិសេស និងដោយឡែក។

ជាខ្លឹមសាររួម ការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលមានប្រទេសជាសមាជិកចំនួន៧០ (គិតត្រឹមឆ្នាំ២០០៥) មានបំណងដើម្បីធានាឱ្យមានយុត្តិធម៌សម្រាប់ប្រទេសសមាជិក WTO ទាំងអស់ដែលកំពុងសកម្មប្រតិបត្តិការវិស័យពាណិជ្ជកម្មក្នុងយុគសម័យសកលភាវូបនីយកម្ម។ ជាក់ស្ដែងលើមូលដ្ឋានចក្ខុវិស័យ WTO គេបានធ្វើការជាច្រើនទាក់ទងដល់វិស័យច្បាប់ពាណិជ្ជកម្មសេវាកម្មទាំងក្នុងក្របខ័ណ្ឌតំបន់ និងក្របខ័ណ្ឌពិភពលោក។ កិច្ចការច្បាប់ពាណិជ្ជកម្ម សេវាកម្មមួយផ្នែកធំបានផ្ដើមចេញពីអង្គការសមាគមអាជីពដែលពាក់ព័ន្ធ ដូចជាអង្គការសហព័ន្ធវិស្វកម្មអាស៊ាន (AFEO) អង្គការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិច (APEC) និងវេទិកាចល័តភាពវិស្វករ (Engineers Mobility Forum: EMF) ជាដើម។

## ទំស័យសេវាកម្មក្នុងតំបន់អាស៊ាន[១]

ការបង្កើតនូវកិច្ចព្រមព្រៀងបណ្ដាញខាងពាណិជ្ជកម្មសេវាកម្មតំបន់អាស៊ាន (AFAS) មានប្រយោជន៍សំខាន់ដើម្បីប្រសិទ្ធភាពពាណិជ្ជកម្មដោយសមាជិកមានលទ្ធភាពទទួលនូវព័ត៌មានទូលំទូលាយ និងគ្រប់គ្រាន់ពីគ្នា។ រដ្ឋសមាជិកទាំងអស់ជាញឹកញយបានជួបប្រាស្រ័យគ្នាដែលនឹងបង្កើតទំនាក់ទំនងល្អរវាងដៃគូពាណិជ្ជកម្មនិងគូប្រណាំងប្រជែងផងដែរ។

កិច្ចព្រមព្រៀងស្ដីពីបណ្ដាញសេវាកម្មអាស៊ានបានត្រូវពិភាក្សា ដើម្បីបង្កើតឡើងតម្រូវតាមសំណូមពរសមាហរណកម្មតំបន់ លើមូលដ្ឋាននៃសកលភាវូបនីយកម្មពាណិជ្ជកម្មសេរី ផ្នែកសេវាកម្មក្នុងតំបន់អាស៊ាន ASEAN Free Trade Agreement in Service (AFTAS)។

AFAS បានបង្កើតឡើងនៅខែធ្នូ ឆ្នាំ១៩៩៥។ វឌ្ឍនភាពនៃការកែសម្រួល AFAS ឱ្យមានខ្លឹមសារសមស្របតាមការវិវត្តនិន្នាការពាណិជ្ជកម្ម ត្រូវបានធ្វើជាបន្តបន្ទាប់តាមកិច្ចប្រជុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចប្រទេសជាសមាជិកអាស៊ានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ និងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨។ លទ្ធផលការងារដែលបានសម្រេចឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចសមាជិកសហគមអាស៊ានបានត្រូវពិភាក្សាក្នុងជំនួបកំពូលរដ្ឋាភិបាលប្រទេសជាសមាជិកអាស៊ានចាប់តាំងពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ ក្នុងកំឡុងជំនួបកំពូលអាស៊ានលើកទី ៨ នៅភ្នំពេញឆ្នាំ២០០២ ជំនួបប្រជុំអាស៊ានលើកទី ៩ នៅកោះបាលីឆ្នាំ២០០៣ ជំនួបកំពូលលើកទី១០ នៅទីក្រុងវៀងច័ន្ទឆ្នាំ២០០៤[២] និងជំនួបប្រជុំកំពូលអាស៊ានលើកទី១១ នៅកូឡាឡាំពួរ ឆ្នាំ២០០៥។ ទាំងនោះបង្ហាញនូវតួនាទីគន្លឹះរបស់សេវាកម្មវិស្វកម្មក្នុងពាណិជ្ជកម្មសហស្សវត្សរ៍ថ្មី ហើយការអភិវឌ្ឍជំនាញវិស្វកម្មត្រូវធ្វើជាបន្តបន្ទាប់។

លោក មាស សុខុម
សាស្ត្រាចារ្យផ្នែកទេពកោសល្យស៊ីវិល
នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

(១) របាយការណ៍សិក្ខាសាលា : (-ជ-) ទំព័រ៣៨

(២) President's Messages of CAFEO-22, Yangon, Myanmar-2004, page 3




## ការតុបតែងបន្ទប់រៀន (តចប់)

**ខ-តើគួរតុបតែងបែបណា?**

របៀបតុបតែងផ្ដែកផ្ដួលទៅតាមសភាពបន្ទប់ ទៅតាមចំណង់ចិត្តអ្នកតុបតែង និងទៅតាមប្រភេទវត្ថុតុបតែង។ ដំបូងគួរជម្រាបបង្ហាញវិធីតុបតែងដែលត្រូវចៀសវាង។ វិធីមិនសមរម្យ គឺការគូរ ការឆ្លាក់ ការបាក់ ការបិទជាប់ផ្ទាល់នឹងផ្ទៃជញ្ជាំងតែម្ដង ដូចជាការគូរផែនទីជាដើម ពីព្រោះដល់ពេលមានការសាកពណ៌ ការប្រឡាក់ ការខូចខាត គេពិបាកនឹងលាបពណ៌ ពិបាកនឹងជួសជុលណាស់ ហើយម្យ៉ាងទៀត វិធីតុបតែងនេះពុំអាចបង្កើតសោភ័ណភាពបានគ្រប់គ្រាន់ឡើយ ពីព្រោះផ្ទៃជញ្ជាំងថ្មមិនរលីងរាបស្មើដូចផ្ទៃក្ដារ ឬផ្ទៃក្រដាសឡើយ។

របៀបតុបតែងដែលគេនិយមអនុវត្តទូទៅ គឺការបោះដែកគោលព្យួររូប ឬភ្ជាប់រូប និងផ្ទាំងសុភាសិត។ ចំពោះការប្រើដែកគោល គួរប្រើដែកគោលរឹងពិសេស សម្រាប់បោះលើជញ្ជាំងថ្មតែម្ដងដែលមានលក់តាមហាងលក់កញ្ចក់ទូទៅ។ មុននឹងបោះសម្រេច គួរណាស់ល្វៃលក វាស់វែងឱ្យសម ឱ្យស្មើ ឱ្យល្អ ហើយឱ្យមានឯកភាពចំពោះបន្ទប់ដែលមានសណ្ឋានដូចៗគ្នា។ បោះស្រេចហើយមិនគួរដកដូរកន្លែងចុះឡើងទៀតឡើយ។

សាលាបឋមសិក្សាខ្លះ អនុវិទ្យាល័យខ្លះ វិទ្យាល័យខ្លះ ច្រើននិយមតុបតែងបន្ទប់ដោយប្រើផ្ទាំងកន្ទេលដាក់ក្របឈើព្យួរជាប់នឹងជញ្ជាំងទាំងបីជ្រុង។ លើផ្ទាំងកន្ទេលនេះ គេបិទរូប បិទសុភាសិត បិទគ្រឿងដេរប៉ាក់ ដោយប្រើម្ជុលសង្កត់ជាហេតុងាយស្រួលដល់ការផ្លាស់ប្ដូរ ហើយមិនជាហេតុនាំឱ្យខូចខាតជញ្ជាំងច្រើនផង។ ធ្វើដូច្នេះ យើងឃើញថាជញ្ជាំងនៅល្អស្អាតគង់វង្សដដែល។

ដើម្បីលើកទឹកចិត្តសិស្សឱ្យស្រឡាញ់ថែទាំបន្ទប់រៀនរបស់ខ្លួន គួរតែកុំភ្លេចឱ្យម្ចាស់វត្ថុ បិទ ឬសរសេរឈ្មោះខ្លួនលើវត្ថុតុបតែងទាំងនោះ។

ការតុបតែងល្អពុំមែនស្ថិតនៅលើចំនួនច្រើន ឬគុណភាពប្រណីតនៃវត្ថុតុបតែងទេ ក៏ប៉ុន្តែនៅលើល្បិចចេះរៀបចំឱ្យសមសួន ឱ្យស្មើភាគ ឱ្យស្រឡះភ្នែក។ ដូចនេះមិនគួរព្យួរ ឬបិទឱ្យពាសពេញស្អេកស្កះនោះឡើយ។ ការតុបតែងជ្រុលហួសហេតុ នឹងបង្កើតនូវអសោភ័ណភាពទៅវិញ។

**ច-តើការតុបតែង ការសំអាត របៀបរៀបរយ និងសភាពបន្ទប់ទាក់ទងគ្នាដែរឬទេ?**

បន្ទប់រៀនចាស់កំពុក ដីធូលីពេញកម្រាល ដីសប្រឡាក់ជញ្ជាំង ពីងពាងព័ទ្ធពិតាន ស្នាមដែកគោលវវាម ចង់ខំតុបតែងយ៉ាងណាក៏មិនឡើងដែរ។ និយាយយ៉ាងនេះ ពុំមែនបានសេចក្ដីថា នឹងល្អលុះត្រាតែថ្មីថែសនោះទេ ជំនំក៏បាន ចាស់បន្តិចក៏បាន ឱ្យតែស្អាតបាត រៀបរយសមរម្យ។ ដូច្នេះ លំអទាក់ទងនឹងការសំអាត និងរបៀបរៀបរយជាដាច់ខាត។ បើយល់ច្បាស់ដូច្នេះហើយ ហើយបើបានជាមានតារាងសិស្សសំអាតថ្នាក់គ្រប់បន្ទប់រៀន គ្រប់សាលារៀនដូច្នេះហើយ គួរណាស់តែចាត់ការឱ្យបានពេញលេញឱ្យហ្មត់ចត់ដូចជា :

- មិនគួរយកព័ត៌មានទៅបិទភ្ជាប់នឹងផ្ទៃជញ្ជាំង ឬនឹងផ្ទៃក្ដារខៀនឡើយ ពីព្រោះស្នាមរបកនៅជិតប្រឡាក់ជាប់ជានិច្ច កែមិនឡើង ជាពិសេសលើជញ្ជាំងថ្ម
- មិនគួរបោសសំអាតត្រឹមតែកម្រាលមួយមុខប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវសំអាតរហូតដល់ស្លាបព្រិល ទ្វារបង្អួច មុំជញ្ជាំង ផ្ទៃពិតានថែមទៀត
- មិនគួរបោសផ្ទុកសំរាមចោលក្រោមជើងកំណល់តុគ្រូ ឬជើងកំណល់ក្ដារខៀន គ្រាន់តែថ្លីនភ្នែកនោះឡើយ បានជាសំអាតហើយ ត្រូវសំអាតទាំងក្រៅទាំងក្នុង (គួរមានល្អី ឬធុងសំរាមមួយប្រចាំបន្ទប់រៀន)
- មិនគួរគ្រាន់តែបោសប៉ុណ្ណោះទេ តែគួរជូតលាង ដុស ខាត់ខ្លះផង ពីព្រោះតុកៅអីសិស្ស និងគ្រូខ្លះមិនស្អាត ប្រឡាក់ប្រឡូសច្រើន ក្នុងករណីនេះ គួរណាស់តែសិស្សម្នាក់ៗមានកំណាត់សំពត់ទុកប្រចាំថតតុតែរៀងៗខ្លួន សម្រាប់ជូតសំអាតមុននឹងប្រើប្រាស់តុកៅអី
- មិនគួរគ្រាន់តែបោសសំអាតប៉ុណ្ណោះទេ តែគួររៀបចំតម្រង់ជួរតុកៅអីឱ្យសមរម្យតាមទីកន្លែងផង
- មិនគួរគ្រាន់តែសំអាត និងរៀបចំតែប៉ុណ្ណោះទេ បើអាចធ្វើទៅបានគួរណាស់តែគ្រូ-សាស្ត្រាចារ្យផ្នែកវិជ្ជាជាងឈើដោយមានសហប្រតិបត្តិការពីទីចាត់ការ និងពីគ្រូ-សាស្ត្រាចារ្យមុខវិជ្ជាផ្សេងៗនាំសិស្សឱ្យជួសជុល តុកៅអីរង្គើ ឬបាក់បែកក្នុងបន្ទប់នីមួយៗនៅពេលធ្វើការងារហត្ថកម្ម (ពុំមែនក្នុងពេលម៉ោងរៀនវិជ្ជាសកម្មភាពប្រតិបត្តិ)។

## ឆ_តើគួរឱ្យតម្លៃបែបណាទៅលើការតុបតែង?

ដើម្បីឱ្យមានប្រសិទ្ធភាព និងការខិតខំ ការតុបតែងបន្ទប់រៀនគួរតែទទួលតម្លៃអ្វីម្យ៉ាងជាការសរសើរលើកទឹកចិត្តក្ដីជាការជូនរង្វាន់ក្ដី ពុំមែនចំពោះតែគ្រូ-សាស្ត្រាចារ្យទទួលភារៈមើលការខុសត្រូវប្រចាំបន្ទប់ ឬក៏ចំពោះតែសិស្សទាំងអស់ក្នុងបន្ទប់ ក៏ប៉ុន្តែចំពោះគ្រូ-សាស្ត្រាចារ្យផង ចំពោះសិស្សផងរួមគ្នាតែម្ដង។ ចំពោះរឿងឱ្យតម្លៃនេះ ទីចាត់ការគប្បីបង្កើតគណៈកម្មការចម្រុះគ្រូ-សាស្ត្រាចារ្យ និងសិស្ស សម្រាប់វិនិច្ឆ័យការតុបតែងនេះ។ នឹងមានការខិតខំតុបតែងដោយយកចិត្តទុកដាក់បាន លុះត្រាមានការវិនិច្ឆ័យតម្លៃលើការខិតខំនោះ ៕

កែសម្រួលដោយលោក **ចែម ផាន**

**អធិការបឋមសិក្សា ជំនាន់ទី១**

**បញ្ជាក់:** អត្ថបទនេះបានទទួលការពិនិត្យ និងយោបល់ស្របពីស.ហ. **កែវ ចែម** នាយកមធ្យមសិក្សា និងពីស.ហ. **ខៀវ កុមារ** អធិការអមទីស្ដីការរដ្ឋមន្ត្រី។

# ការដឹកនាំ និងការគ្រប់គ្រង (ត)

**៩_ដឹកនាំគឺមានប្រឌិតញាណ ឯគ្រប់គ្រងគឺប្រព្រឹត្តតាម** (Leading is being creative while managing is following)

ប្រព្រឹត្តតាម គឺអនុវត្តតាមការណែនាំ ឬធ្វើនូវអ្វីដែលអ្នកឯទៀតបានធ្វើរួចហើយ។ មាននាយកសាលាជាច្រើនដែលពូកែក្នុងការធ្វើឱ្យសម្រេចនូវការណែនាំពីថ្នាក់លើ និងចម្លងនូវមេរៀនល្អៗពីសាលាដទៃទៀត។ គាត់គឺជាអ្នកគ្រប់គ្រងដ៏ល្អ។ ប្រឌិតញាណ គឺជាសមត្ថភាពបង្កើតនូវអ្វីដែលថ្មីលើមូលដ្ឋាននៃវត្ថុដែលមានហើយ។ មនុស្សដែលមានប្រឌិតញាណមានភាពប៉ិនប្រសប់ក្នុងការប្រើប្រាស់វត្ថុដែលមានស្រាប់ក្នុងគោលដៅផ្សេង ឬក្នុងផ្លូវផ្សេង។ នាយកសាលាដែលមានប្រឌិតញាណអាចធ្វើដើមឈើ ឬដើមត្នោតមួយដើមក្នុងទីធ្លាសាលាឱ្យមានសោភ័ណភាពកាន់តែទាក់ទាញសាធារណជនជាជាងកាប់វាចោល។ ក្នុងពេលដែលសម្ភារៈរៀនកំពុងតែខ្វះខាត នាយកសាលាដែលមានប្រឌិតញាណអាចមានសមត្ថភាពជួយគ្រូឱ្យប្រើប្រាស់សម្ភារៈដែលមានស្រាប់ក្នុងមូលដ្ឋានជាសម្ភារៈរៀនប្រកបដោយប្រសិទ្ធភាព។ ក្នុងទេវកថា អង្គរធំ ជាតំណាងភ្នំព្រះសុមេរ៉ុ ឯទឹកព័ទ្ធជុំវិញជានិមិត្តរូបនៃមហាសមុទ្រ។ ប៉ុន្តែព្រះបាទជ័យវរ្ម័នទី ៧ បានប្រើទឹកនេះជាប្រយោជន៍ក្នុងការងារកសិកម្ម។ ព្រះអង្គបានបង្ហាញនូវប្រឌិតញាណខ្ពស់។ ការប្រព្រឹត្តតាមមិនអាចធ្វើឱ្យមានការប្រែប្រួលទេ ផ្ទុយទៅវិញប្រឌិតញាណជួយឱ្យមានការរីកចំរើនជាបន្តបន្ទាប់។ នាយកសាលាដែលមានប្រឌិតញាណ នឹងធ្វើឱ្យសាលារបស់គាត់ប្រែប្រួលជាប់ជានិច្ចនោះ គឺជាអ្នកដឹកនាំដ៏ល្អ។

**១០_ដឹកនាំគឺលើកកំពស់ការប្រែប្រួលតាមបែបច្នៃប្រឌិត ឯគ្រប់គ្រងគឺថែរក្សាអ្វីដែលមានតាមស្ថានភាពរបស់វា** (Leading is promoting creative changes while managing is maintaining things the way they are)

មូលដ្ឋានជាសារវន្តនៃប្រាសាទនៅអង្គរទាំងអស់ដូចគ្នា គឺប្រាសាទនីមួយៗជារូបភាពតាងសកលលោក។ ប៉ុន្តែក្នុងការកសាងប្រាសាទទាំងអស់ខុសគ្នាពីមួយទៅមួយ។ ប្រាសាទនីមួយៗសុទ្ធតែបង្ហាញនូវរចនាបថដោយឡែកៗរបស់ខ្លួន។ ប្រាសាទបន្ទាយស្រី ល្បីដោយក្បាច់ចម្លាក់ល្អិត ជ្រៅ និងរស់រវើក ប្រាសាទអង្គរវត្តល្បីដោយសារភាពសម្បើម និងល្អិតល្អន់ ក្នុងស្ថាបត្យកម្ម ចំណែកឯប្រាសាទបាយ័នវិញ ល្បីដោយកំពូលមុខបួនញញឹមជានិច្ចទៅរកអ្នកទេសចរ។ ពីប្រាសាទមួយទៅប្រាសាទមួយពិតជាមានការប្រែប្រួលដោយការច្នៃប្រឌិត។ ហេតុនេះហើយបានជាទេសចរ នៅពេលមកដល់អង្គរហើយ គេមិនឆ្អែតតែត្រឹមទស្សនាប្រាសាទអង្គរវត្តមួយទេ គេចង់ដើរមើលគ្រប់ប្រាសាទទាំងអស់។

នាយកសាលាក៏យ៉ាងនេះដែរ។ នាយកសាលាមួយចំនួនអាចធ្វើឱ្យសាលារបស់ខ្លួនប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ទាំងបរិមាណ និងគុណភាព។ ពួកគេជាអ្នកដឹកនាំដ៏ពូកែ។ ប៉ុន្តែក៏មាននាយកសាលាខ្លះមិនហ៊ានសាកល្បងច្នៃប្រឌិតស្វែងរកការប្រែប្រួល។ គាត់ជឿជាក់ថា ភារកិច្ចរបស់គាត់គឺត្រូវថែរក្សានូវអ្វីដែលមានស្រាប់ឱ្យគង់វង្សតែប៉ុណ្ណោះ។ ពួកគាត់ធ្វើបានល្អត្រឹមការគ្រប់គ្រងតែប៉ុណ្ណោះ។

**១១_ដឹកនាំគឺស្រមៃទៅរកអនាគត ឯគ្រប់គ្រងគឺធ្វើការងារដដែលៗប្រចាំថ្ងៃ** (Leading is imagining the future while managing is doing the routine day to day tasks)

មូលហេតុដែលសាលាមួយចំនួនតែងទទួលនូវជោគជ័យជាប់ជានិច្ចនោះ ព្រោះនាយកសាលាទាំងនោះមានក្នុងក្បាលរបស់គេនូវរូបភាពទៅអនាគតនៃសាលាទាំងនោះ។ ផ្អែកតាមរូបភាពនេះ គេកសាងនូវចក្ខុវិស័យ ទិសដៅ វត្ថុបំណង និងផែនការ

សកម្មភាព ហើយប្តេជ្ញាធ្វើឱ្យសម្រេចនូវផែនការនោះ។ ពួកគាត់ទាំងនោះប្រៀបបានទៅនឹងអ្នកដឹកនាំប្រទេសមួយរូបដែលជានិច្ចកាលតែងគិតដល់អនាគតនៃប្រទេសរបស់ខ្លួន។ អ្នកគ្រប់គ្រងមិនគិតដល់អនាគតទេ គេគិតត្រឹមការងារដដែលៗដែលត្រូវធ្វើជាប្រចាំរាល់ថ្ងៃ។

**១២-ដឹកនាំគឺលើកកំពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវនៃមនុស្សគ្រប់រូប ឯគ្រប់គ្រងគឺទទួលខុសត្រូវតែម្នាក់ឯង** (Leading is promoting ownership and responsibility in other while managing is being responsible onself)

ក្នុងជំពូកទីមួយយើងបានកំណត់និយមន័យភាពជាអ្នកដឹកនាំថា ជាលំនាំនៃការបណ្តុះ និងជំរុញមនុស្សឱ្យប្រឹងប្រែងធ្វើការ ធ្វើការកាន់តែប្រសើរឡើង...។ វិធីល្អបំផុតសម្រាប់ជំរុញមនុស្សគឺធ្វើឱ្យគេមានអារម្មណ៍ជាម្ចាស់សាលា។ អារម្មណ៍ជាម្ចាស់លើកកម្ពស់ភាពទទួលខុសត្រូវ និងធ្វើឱ្យមនុស្សមានឆន្ទៈប្រឹងប្រែងធ្វើការ។ អ្នកដឹកនាំលើកកម្ពស់ភាពជាម្ចាស់ដល់មនុស្សទាំងអស់ដោយស្តាប់គេនិយាយ ផ្តល់ឱកាសឱ្យគេគិត និងចែករំលែកគំនិតរវាងគ្នានិងគ្នា ព្រមទាំងផ្តល់ឱកាសឱ្យគេទទួលខុសត្រូវ។ ចំពោះអ្នកគ្រប់គ្រងវិញ គាត់តែងយល់ថា នាយកសាលាត្រូវតែទទួលខុសត្រូវលើគ្រប់ការងារក្នុងសាលា ហើយមិនហ៊ានឱ្យគេរួមចំណែកទទួលខុសត្រូវជាមួយទេ។

មកដល់ត្រឹមនេះ យើងយល់ច្បាស់អំពីការដឹកនាំ និងការគ្រប់គ្រង ព្រមទាំងអាចបង្ហាញនូវភាពខុសគ្នារវាងបញ្ញត្តិទាំងពីរនេះទៀត។ ប៉ុន្តែក្នុងការប្រតិបត្តិ ការដឹកនាំនិងការគ្រប់គ្រងត្រូវប្រព្រឹត្តទៅទន្ទឹមគ្នា នាយកសាលាមិនត្រូវប្រកាន់យកមួយណាចោលមួយណាបានទេ។ នាយកសាលាដែលជាអ្នកដឹកនាំល្អត្រូវពូកែទាំងខាងការដឹកនាំ ទាំងខាងការគ្រប់គ្រង ប៉ុន្តែសាលារបស់យើងត្រូវការយើងជាអ្នកដឹកនាំខ្លាំងពូកែ និងប្រកបដោយប្រសិទ្ធភាព ជាអ្នកគ្រប់គ្រងដ៏ល្អ។

## តើធ្វើដូចម្តេចដើម្បីក្លាយជាអ្នកដឹកនាំប្រកបដោយជោគជ័យ?

### ១.ភាពជាអ្នកដឹកនាំពុំមែនជាឧបនិស្ស័យពីកំណើត តែជាសមត្ថភាពដែលអាចបណ្តុះបណ្តាលបាន

មនុស្សជាច្រើនជឿថា ភាពជាអ្នកដឹកនាំ ជានិស្ស័យពីកំណើត។ ការសន្មតបែបនេះធ្វើឱ្យមនុស្សអស់សង្ឃឹមក្នុងការកែលំអខ្លួនឱ្យក្លាយជាអ្នកដឹកនាំល្អ។ នាយកសាលាជាច្រើនមើលឃើញខ្លួនឯង អសមត្ថភាព ដោយហេតុថា ខ្លួនពុំមានឧបនិស្ស័យជាអ្នកដឹកនាំពូកែ។ ពួកគាត់តែងពោលថា "ខ្ញុំបានប្រឹងប្រែងអស់លទ្ធភាពហើយ។ ខ្ញុំមិនមានសមត្ថភាពគ្រប់គ្រាន់អាចក្លាយជាអ្នកដឹកនាំពូកែបានទេ"។ តើពិតជាមានមនុស្សខ្លះមាននិស្ស័យដឹកនាំពីកំណើតមែនឬ? តើជាការពិត ទេដែលយើងម្នាក់ៗមិនអាចក្លាយជាអ្នកដឹកនាំខ្លាំងពូកែបាន?

កន្លងមក ពុំមានភស្តុតាងបញ្ជាក់ថា មនុស្សមានលក្ខណៈសួរពូជខាងជំនាញ និងសមត្ថភាពទេ។ វាជាការពិតដែលថាមានមនុស្សខ្លះបានទទួលជាតំណពូជពីឪពុកម្តាយរបស់ខ្លួននូវលក្ខណៈមួយចំនួន។ វាជាការពិតដែលមានតន្ត្រីករ អ្នកចម្រៀង ឬវិចិត្រករមួយចំនួនមានជំនាញពិសេសអាចអភិវឌ្ឍឱ្យមានភាពល្បីល្បាញតាំងតែពីនៅវ័យក្មេង។ ប៉ុន្តែវាក៏ជាការពិតដែរដែលពុំមានជាប់លោហិតជាអ្នកចម្រៀង ឬជាសិល្បករសោះ តែដោយការហ្វឹកហាត់ ការខំប្រឹងប្រែងតស៊ូព្យាយាម ពួកគេបានក្លាយជាមនុស្សមានកេរ្តិ៍ឈ្មោះល្បីល្បាញ។ ភាពជាអ្នកដឹកនាំក៏យ៉ាងនេះដែរ ព្រះបាទជ័យវរ្ម័នទី៧ ជាក្សត្រមួយអង្គដែលមានសមត្ថភាពដឹកនាំខ្លាំងពូកែ ប៉ុន្តែចំពោះព្រះរាជបុត្ររបស់ព្រះអង្គវិញនោះ ពុំមានបុត្រអង្គណាមានសមត្ថភាពដឹកនាំពូកែដូចព្រះអង្គឡើយ។ ប្រសិនបើភាពជាអ្នកដឹកនាំ មានលក្ខណៈសួរពូជនោះ រាជបុត្ររបស់ព្រះអង្គក៏ជាអ្នកដឹកនាំពូកែដូចព្រះអង្គដែរ ហើយភាពរុងរឿងនៃសម័យអង្គរពិតជាមិនត្រូវបានបញ្ចប់ទេ។ វាក៏មានភស្តុតាងបញ្ជាក់ផងដែរថា បន្ទាប់ពីបានសិក្សា និងអនុវត្តជាក់ស្តែងរួចមក សមត្ថភាពដឹកនាំរបស់នាយកសាលាជាច្រើនត្រូវបានកែលំអ។ ដូចនេះ ភាពជាអ្នកដឹកនាំមិនមែនមានមកពីកំណើតទេ

តែគេអាចបណ្ដុះបណ្ដាលវាបាន។ នាយកសាលាម្នាក់ៗគួរតែតាំងចិត្តរៀនសូត្រ និងអភិវឌ្ឍឱ្យបានក្លាយជាអ្នកដឹកនាំដ៏ខ្លាំងពូកែ។ ត្រូវគិតថា យើងអាចធ្វើបាន ហើយដើម្បីធ្វើឱ្យបាននោះ លក្ខខណ្ឌដំបូង គឺត្រូវតែមានជំនឿ និងទំនុកចិត្តលើខ្លួនឯង ហើយត្រូវអភិវឌ្ឍសមត្ថភាពរបស់យើង។

**២.** **<u>តើត្រូវអភិវឌ្ឍសមត្ថភាពដឹកនាំដោយវិធីណា?</u>** (How to build the leadership capacity?)

នាយកសាលាជាច្រើនមានឆន្ទៈចង់ក្លាយជាអ្នកដឹកនាំដ៏ខ្លាំងពូកែ ប៉ុន្តែប្រការដែលគួរឱ្យស្ដាយនោះគឺក្នុងដំណើរការកែលំអនេះ ពួកគេបានទទួលនូវការជួយគាំទ្រតិចតួចបំផុត។ នៅប្រទេសយើងសៀវភៅជាភាសាជាតិដែលនិយាយពីភាពជាអ្នកដឹកនាំមានតិចតួចបំផុត ហើយសិក្ខាសាលានានាដែលទាក់ទងដល់ការដឹកនាំនោះមានត្រឹមតែជាគំនិតផ្ដើមមិនអាចជួយទ្រទ្រង់ការអភិវឌ្ឍយូរអង្វែងបាន។ ជាធម្មតា កាលណានិយាយដល់ភាពជាអ្នកដឹកនាំ គេតែងយោងទៅរកបញ្ជីលក្ខណៈផ្សេងៗដែលជាសមត្ថភាពនៃអ្នកដឹកនាំល្អដែលគេឱ្យឈ្មោះថា "លក្ខណៈនៃអ្នកដឹកនាំខ្លាំងពូកែ (Characteristics of a great leader)"។ នាយកសាលាទាំងឡាយត្រូវបានស្នើសុំឱ្យយកចិត្តទុកដាក់ដល់លក្ខណៈនីមួយៗ ហើយគិតពីវិធីកែលំអទៅតាមលក្ខណៈនេះ។ នាយកសាលាភាគច្រើនបានខិតខំប្រឹងប្រែងកែលំអខ្លួន តែការប្រែប្រួលនៅយឺតយ៉ាវនៅឡើយ។ មូលហេតុសំខាន់នៃការយឺតយ៉ាវនេះ គឺពួកគាត់គិតទៅលើលក្ខណៈនីមួយៗ ជាលក្ខណៈទោលមិនទាក់ទងគ្នា។ តាមការពិត លក្ខណៈនៃអ្នកដឹកនាំ ជាលក្ខណៈដែលប្រទាក់ប្រទងគ្នា និងមានប្រតិកម្មរវាងគ្នានឹងគ្នា។ វាមិនដូចជាសត្វគោនៅក្នុងហ្វូងគោនោះទេ។ ក្នុងហ្វូងគោមួយ សត្វគោមួយងាប់ទៅ ហ្វូងគោនៅតែជាហ្វូងគោដដែល ប៉ុន្តែដោយឡែកចំពោះភាពជាអ្នកដឹកនាំ ប្រសិនបើអ្នកដឹកនាំណាម្នាក់មានចំណុចខ្វះខាតលើលក្ខណៈណាមួយហើយនោះ ចំណុចខ្វះខាតនោះនឹងជះឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំរបស់គាត់ទាំងមូល។ ការអភិវឌ្ឍភាពជាអ្នកដឹកនាំគឺជាលំនាំអភិវឌ្ឍទាំងស្រុង និងសុខដុម។ គ្រប់នាយកសាលាត្រូវយល់ច្បាស់ថា គ្រប់លក្ខណៈនៃភាពជាអ្នកដឹកនាំមូលចូលគ្នា និងប្រទាក់ប្រទងគ្នាពីមួយទៅមួយ។

យើងអាចប្រៀបធៀបភាពជាអ្នកដឹកនាំទៅនឹងផ្ទះមួយ។ ផ្ទះមួយដែលរឹងមាំល្អទាមទារនូវគ្រឹះរឹងមាំ។ មានគ្រឹះរឹងមាំយើងអាចសង់ផ្ទះច្រើនជាន់បាន។ គ្រឹះនៃភាពជាអ្នកដឹកនាំ គឺស្វ័យឱ្យតម្លៃ និងការឱ្យតម្លៃនៃអ្នកដឹកនាំ។ ប្រសិនបើអ្នកដឹកនាំពុំបានគិតថា ខ្លួនមានតម្លៃ ខ្លួនមានសមត្ថភាព ខ្លួនអាចធ្វើបាន និងពុំបានយល់ពីតម្លៃក្នុងសង្គមទេ នោះគេពុំអាចក្លាយជាអ្នកដឹកនាំខ្លាំងពូកែបានទេ។

បន្ទាប់ពីគ្រឹះផ្ទះត្រូវការនូវសសរដើម្បីទ្រដំបូល។ ប្រសិនបើមានសសររឹងមាំ យើងអាចច្នៃដំបូលបែបណាក៏បាន។ ម្យ៉ាងទៀតក៏ត្រូវមានចំនួនសសរគ្រប់គ្រាន់តាមទំហំផ្ទះ ចំនួនសសរកាន់តែច្រើនទំហំផ្ទះក៏កាន់តែធំទៅតាមនោះ។ ក្នុងភាពជាអ្នកដឹកនាំ សសរគឺជាចំណេះដឹង និងបំណិននៃអ្នកដឹកនាំ។ ចំណេះដឹង និងបំណិនកាន់តែទូលាយ អ្នកដឹកនាំក៏កាន់តែខ្លាំងពូកែទៅតាមនោះដែរ។ ផ្ទះគឺជាលទ្ធផល អ្នកដឹកនាំមិនអាចសម្រេចបាននូវលទ្ធផលល្អទេ ប្រសិនបើគេគ្មានចំណេះដឹង និងបំណិនខ្លាំងពូកែនោះ។ សសរខ្លួនឯងនឹងមិនរឹងមាំបានទេ ប្រសិនបើគ្មានជញ្ជាំង និងគ្រឿងលើសម្រាប់ទ្រដំបូល។ ក្នុងភាពជាអ្នកដឹកនាំ ជញ្ជាំងគឺជាការងារជាក្រុម និងគ្រឿងលើជាទំនាក់ទំនង។ ការប្រៀបធៀបនេះអាចមានន័យគ្រប់គ្រាន់ក្នុងការជួយឱ្យយល់នូវអន្តរទំនាក់ទំនងរវាងទិដ្ឋភាពផ្សេងៗនៃភាពជាអ្នកដឹកនាំ : ស្វ័យឱ្យតម្លៃ ការឱ្យតម្លៃ ចំណេះដឹង និងបំណិន។ នាយកសាលាត្រូវតែយល់នូវបញ្ហានេះ ហើយសម្លឹងមើលទៅភាពជាអ្នកដឹកនាំជារូបភាពទាំងមូល។ ដើម្បីក្លាយជា អ្នកដឹកនាំពូកែម្នាក់ៗត្រូវផ្ដោតទៅលើគ្រប់លក្ខណៈទាំងអស់នៃភាពជាអ្នកដឹកនាំ៕

**លោក អ៊ុំច សារិត់**

**មន្ត្រីចូលនិវត្តន៍ ខេត្តតាកែវ**

# មូលភេទ អ-អ៊ (ត)

ក្បួនប្រាប់ស្រៈក្នុងពាក្យខ្មែរយើង ច្រើនអនុវត្តចំពោះពាក្យមួយព្យាង្គ និងពាក្យពីរព្យាង្គ។ យើងសង្កេតឃើញថា ក្នុងពាក្យខ្មែរយើងខ្លះ មានឥទ្ធិពលមូលភេទរវាងព្យញ្ជនៈ និងព្យញ្ជនៈ ហើយពាក្យខ្មែរខ្លះទៀតពុំមានឥទ្ធិពលមូលភេទរវាងព្យញ្ជនៈ និងព្យញ្ជនៈទេ។ ដូចនេះ ក្បួនប្រាប់ស្រៈក្នុងពាក្យមួយព្យាង្គក្ដី ក្នុងពាក្យពីរព្យាង្គក្ដី មាន ២ ករណី គឺករណីមានឥទ្ធិពលមូលភេទ និងករណីគ្មានឥទ្ធិពលមូលភេទ។

ក្បួនប្រាប់ស្រៈពុំមានចោទជាបញ្ហាទេ :

- ក្នុងពាក្យមួយព្យាង្គដែលមានតែ ព្យញ្ជនៈ + ស្រៈ ឬព្យញ្ជនៈ + ស្រៈ + ព្យញ្ជនៈ ព្រោះសញ្ញាព្យញ្ជនៈដើមព្យាង្គជាអ្នកកំណត់សូរស្រៈជាពួក អ ឬពួក អ៊ ដោយខានពុំបាន។
- ក្នុងពាក្យមួយព្យាង្គ ឬក្នុងពាក្យពីរព្យាង្គ ដែលមានព្យញ្ជនៈទាក់ទងគ្នា ស្ថិតនៅក្នុងមូលភេទជាមួយគ្នា។

## ក-ក្បួនប្រាប់ស្រៈក្នុងពាក្យមួយព្យាង្គ

ពាក្យមួយព្យាង្គមានទំរង់ ៤ យ៉ាងគឺ :

- ព្យញ្ជនៈ + ស្រៈ (ព + ស) ÷ ក គឺ ត ទា បី...
- ព្យញ្ជនៈ + ស្រៈ + ព្យញ្ជនៈ (ព + ស + ព) ÷ កាក ទៀង ពង់ គាប់...
- ព្យញ្ជនៈ + ព្យញ្ជនៈ + ស្រៈ (ព + ព + ស) ÷ ក្រ គ្រី ថ្មី ផ្ញើ ស្មើ...
- ព្យញ្ជនៈ + ព្យញ្ជនៈ + ស្រៈ + ព្យញ្ជនៈ (ព + ព + ស + ព) ÷ ខ្ពើម គ្មាន ព្រាប ល្មោន...។

ក្នុងទម្រង់ ព + ព + ស និង ព + ព + ស + ព ព្យញ្ជនៈពីរតួនៅខាងដើមព្យាង្គ ជាសញ្ញាព្យញ្ជនៈផ្សំដើមព្យាង្គ។ សញ្ញាព្យញ្ជនៈទី១ ហៅថា សញ្ញាព្យញ្ជនៈធាតុទី១ នៃសញ្ញាព្យញ្ជនៈផ្សំដើមព្យាង្គ។ សញ្ញាព្យញ្ជនៈធាតុទី១នេះ សរសេរកាត់ជា ព$_{១}$។ សញ្ញាព្យញ្ជនៈទី២ ហៅថា សញ្ញាព្យញ្ជនៈធាតុទី២ នៃសញ្ញាព្យញ្ជនៈផ្សំដើមព្យាង្គ។ សញ្ញាព្យញ្ជនៈធាតុទី២នេះសរសេរកាត់ជា ព$_{២}$។ ដូចនេះ ពាក្យមួយព្យាង្គអាចមានទំរង់ដូចនេះ : [ព$_{១}$ ព$_{២}$ ស] និង [ព$_{១}$ ព$_{២}$ ស ព$_{៣}$] (ព$_{៣}$ ជាព្យញ្ជនៈប្រកប)។

### ករណីមានឥទ្ធិពលមូលភេទ

ក្នុងពាក្យមួយព្យាង្គ ពេលខ្លះ ព$_{១}$ អាចមានឥទ្ធិពលមូលភេទទៅលើ ព$_{២}$ បានសេចក្ដីថា ព$_{១}$ អាចនាំ ព$_{២}$ ឱ្យប្ដូរមូលភេទបាន ដោយមិនចាំបាច់ប្រើវណ្ណយុត្តិ។

#### ក.១-ក្បួនទី១

ឧទាហរណ៍ : ផ្ញើ ប្រើ ស្នើ ខ្ពើត ច្រើង ស្បាម...។

វិភាគពាក្យ ផ្ញើ : ផ ជាពួក អ ក្នុងក្រុម ១ ដែលជាក្រុមខ្លាំង ឬ "ផ ជា អ$_{១}$"

ញ (្ញ) ជាពួក អ៊ ក្នុងក្រុម ២ ដែលជាក្រុមខ្សោយ ឬ "ញ ជា អ៊$_{២}$"

ញ ត្រូវប្ដូរមូលភេទតាមមូលភេទរបស់ ផ ជាពួក អ វិញ។

ដូចនេះ ផ្ទ (ជាពួក អ) + ើ > ផ្ទើ (ជាព្យាង្គពួក អ) ។

ទម្រង់ : [ព$_{១}$ ព$_{២}$ ស]

រូបមន្ត : ព$_{១}$ + ព$_{២}$ > ព$_{១}$ព$_{២}$

ព$_{១}$ ជា អ$_{១}$ + ព$_{២}$ ជា អ៊$_{២}$ > ព$_{១}$ព$_{២}$ ជាពួក អ

ធាតុទី១ ធាតុទី២ ធាតុផ្សំ

ក្នុងទីនេះ ព$_{១}$ មានឥទ្ធិពលនាំឱ្យ ព$_{២}$ ប្តូរមូលភេទជាពួក អ ដោយមិនចាំបាច់ប្រើវណ្ណយុត្តិមូសិកទន្ត ( ៉ ) ។

**ក្បួន** : ក្នុងពាក្យមួយព្យាង្គ [ព$_{១}$ ព$_{២}$ ស ឬ ព$_{១}$ ព$_{២}$ ស ព$_{៣}$] កាលណាសញ្ញាព្យញ្ជនៈធាតុទី១ (ព$_{១}$) ជាពួក អ$_{១}$ ហើយសញ្ញាព្យញ្ជនៈធាតុទី២ (ព$_{២}$) ជាពួក អ៊$_{២}$ សញ្ញាព្យញ្ជនៈផ្សំដើមព្យាង្គ (ព$_{១}$ព$_{២}$) ជាពួក អ គឺថា ព$_{១}$ ជាអ្នកកំណត់សូរស្រៈពួក អ ។

**ឧទាហរណ៍បញ្ជាក់ :**

ក + ង > ក្ង : ក្ង ក្ងក់ ក្ងង់ ក្ងាន ក្ងិងក្ងង់ ក្ងិច ក្ងិត ក្ងុក ក្ងុង ក្ងុល ក្ងុះ ក្ងេះ ក្ងែង ក្ងោក

ក + ន > ក្ន : ក្នក់ ក្នាញ់ ក្និកក្នក់ ក្នក់ក្និក ក្និច ក្នុង

ក + ម > ក្ម : ក្មួយ ក្មេក ក្មេងក្មាង

ក + រ > ក្រ : ក្រ ក្រក ក្រង ក្រង់ ក្រា ក្រាញ់ ក្រុង ក្រី ក្រឹម ក្រើស ក្រាំង

ក + ល > ក្ល : ក្លង ក្លម ក្លស់ ក្លា ក្លាត់ ក្លាយ ក្លិន ក្លឹស ក្លុក ក្លើ ក្លែង ក្លែប ក្លុំ ក្លំ

ក + វ > ក្វ : ក្វាត ក្វែន

ខ + ញ > ខ្ញ : ខ្ញក ខ្ញង់ ខ្ញាក ខ្ញាល់ ខ្ញិកខ្ញុក ខ្ញី ខ្ញឹង ខ្ញុង ខ្ញូច ខ្ញើច ខ្ញែម ខ្ញែរ

ខ + ន > ខ្ន : ខ្នង ខ្នប់ ខ្នល់ ខ្នន់ ខ្នាច ខ្នាន់ខ្នាប់ ខ្នាប ខ្នាយ ខ្នារ ខ្នីប ខ្នុរ ខ្នោះ

ខ + ម > ខ្ម : ខ្មង ខ្មាញ់ ខ្មាន់ ខ្មាយ ខ្មីឃ្មាត ខ្មឹត ខ្មុក ខ្មុល ខ្មួត ខ្មួញ ខ្មួរ ខ្មែរ

ខ + យ > ខ្យ : ខ្យង ខ្យល់ ខ្យាដីរ

ខ + ល > ខ្ល : ខ្លប ខ្លា ខ្លាច ខ្លាញ់ ខ្លី ខ្លឹម ខ្លឹត ខ្លុក ខ្លុង ខ្លួត ខ្លោង ខ្លោត ខ្លុះ

ខ + វ > ខ្វ : ខ្វក ខ្វង ខ្វាត់ ខ្វាន់ ខ្វិត ខ្វិន ខ្វិល ខ្វេរ ខ្វែក ខ្វែវ ខ្វែះ ខ្វោក

ច + ន > ចន្ន : ច្នេះ ច្នៃ ច្នោះ

ច + រ > ច្រ : ច្រក ច្រាង ច្រាច់ ច្រាន ច្រិមច្រុម ច្រឹង ច្រុប ច្រូត ច្រេះ ច្រែះ

ឆ + ង > ឆ្ង : ឆ្ងក ឆ្ងក់ ឆ្ងល់ ឆ្ងាញ់ ឆ្ងាយ ឆ្ងិត ឆ្ងឹង ឆ្ងុយ ឆ្ងូវ ឆ្ងើក ឆ្ងើយ ឆ្ងែឆ្ងល់

ឆ + ន > ឆ្ន : ឆ្នង់ ឆ្នាក់ ឆ្នាប់មាត់ ឆ្នាល់ ឆ្នាស ឆ្នឹម ឆ្នុក ឆ្នូត ឆ្នើម ឆ្នោរ ឆ្នែង ឆ្នៃ

ឆ + ម > ឆ្ម : ឆ្មក់ ឆ្មប ឆ្មា ឆ្មាត់ ឆ្មារ ឆ្មូល ឆ្មើងឆ្មៃ ឆ្មាំ

ឆ + ល > ឆ្ល : ឆ្លក ឆ្លង ឆ្លា ឆ្លាក់ ឆ្លាត ឆ្លាម ឆ្លាស់ ឆ្លឹម ឆ្លុះ ឆ្លូក ឆ្លើយ ឆ្លែក

ឆ + វ > ឆ្វ : ឆ្វង់ ឆ្វា ឆ្វាក ឆ្វាក់ ឆ្វាង ឆ្វាច ឆ្វាត់ឆ្វែង ឆ្វាយ ឆ្វេង ឆ្វេះ ឆ្វែល

ត + ង > ត្ង : ត្ងោក

ត + ន > ត្ន : ត្នោត

ត + ម > ត្ម : ត្មាត ត្មិល ត្មោង ត្មោល ត្មះ

ត + រ > ត្រ : ត្រ ត្រក ត្រក់ ត្រង ត្រង់ ត្រា ត្រាង ត្រាច ត្រាច់ ត្រិល ត្រី ត្រើយ

ត + ល > ត្ល : ត្លឹង ត្លុក ត្លុង ត្លុម ត្លៅ ត្លែ ត្លែត ត្លោត ត្លុំ

ត + វ > ត្វ : ត្វា ត្វាង

ថ + ង > ថ្ង : ថ្ង ថ្ងប ថ្ងាន់ ថ្ងាស ថ្ងិចថ្ងរ ថ្ងុង ថ្ងុញ ថ្ងុយ ថ្ងូរ ថ្ងូវ ថ្ងៃ

ថ + ន > ថ្ន : ថ្នក់ ថ្នង ថ្នម ថ្នរ ថ្នល់ ថ្នាក់ ថ្នឹក ថ្នូរ ថ្នេរ ថ្នោល ថ្នាំ ថ្នាំង

ថ + ម > ថ្ម : ថ្ម ថ្មាត់ ថ្មារ ថ្មី ថ្មើរ ថ្មៃ ថ្មោង

ថ + ល > ថ្ល : ថ្លង់ ថ្លា ថ្លាង ថ្លាញ់ ថ្លាន់ ថ្លឹង ថ្លុក ថ្លើង ថ្លើម ថ្លែង ថ្លែន ថ្លៃ

ថ + វ > ថ្វ : ថ្វាក ថ្វាង ថ្វាត់ ថ្វាយ ថ្វិច ថ្វី ថ្វីបើ ថ្វើយ ថ្វីហ:ថ្វីហើយ ថ្វៃ

ប + រ > ប្រ : ប្រក់ ប្រកាច់ ប្រា ប្រាប ប្រិត ប្រី ប្រុង ប្រូង ប្រេង

ប + ល > ប្ល : ប្លម ប្លាញៗ ប្លិក ប្លិច ប្លឹម ប្លុង ប្លេងប្លោង ប្លែក ប្លែង ប្លោក

ផ + ង > ផ្ង : ផ្ងក់ៗ ផ្ងាក ផ្លាក់ផ្ងើក ផ្ងារ ផ្ងាវ ផ្លុប ផ្លុត ផ្ងើយ ផ្ងំ

ផ + ញ > ផ្ញ : ផ្ញាច់ៗ ផ្ញាញៗ ផ្ញុក ផ្ញុច ផ្ញើ ផ្ញោញៗ

ផ + ន > ផ្ន : ផ្នត់ ផ្នូកខ្សាច់ ផ្នូត ផ្នូរ ផ្នូល ផ្នែក ផ្នោះ

ផ + ល > ផ្ល : ផ្លាន ផ្លិត ផ្លូន ផ្លើស ផ្លេកផ្លោះ ផ្លែ ផ្លែង ផ្លោង ផ្លុំ

ស + ង > ស្ង : ស្ងប់ ស្ងាច ស្ងាត់ ស្ងាប ស្ងើក ស្ងើច ស្ងើន ស្ងោរ

ស + ញ > ស្ញ : ស្ញក់ ស្ញប់ ស្ញាញ ស្ញុកស្ញូវ ស្ញុរ ស្ញូញ ស្ញើប ស្ញេញ ស្ញែង

ស + ន > ស្ន : ស្ន ស្នង ស្នប ស្នាច ស្និត ស្នឹម ស្នូក ស្នើ ស្នែង ស្នោ ស្នំ

ស + ម > ស្ម : ស្មង ស្មន់ ស្មាច់ ស្មាញ ស្មាន ស្មិង ស្មិត ស្មុត ស្មូម ស្មេរ

ស + យ > ស្យ : ស្យា ស្យាម ស្យុល

ស + រ > ស្រ : ស្រក ស្រង់ ស្រា ស្រាង ស្រិត ស្រី ស្រែង ស្រែះ ស្រំ ស្រាំ

ស + ល > ស្ល : ស្ល ស្លង់ ស្លប ស្លា ស្លាក់ ស្លាត ស្លុត ស្លូត ស្លើត ស្លេវ ស្លែ

ស + វ > ស្វ : ស្វត ស្វា ស្វាក់ ស្វាង ស្វាត ស្វាន ស្វាយ ស្វិត ស្វែង ស្វះ

អ + វ > អ្វ : អ្វី...។

(នៅមានត)

លោក ស្វ មួយឃឿង

# គណិតវិទ្យា

## ការដោះស្រាយចំណោទ (ត)

### III- ឧទាហរណ៍ចំណោទប្រភេទទី៣

បន្ទាប់ពីនេះទៅ គឺជាចំណោទទាំងឡាយដែលអាចជួយសិស្សឱ្យចេះស្រាវជ្រាវ ដោះស្រាយរកចម្លើយដើម្បីកសាងចំណេះដឹងផ្ទាល់ខ្លួនរបស់គេ ដើម្បីឱ្យសមស្របទៅនឹងគោលវិធីសិស្សមជ្ឈមណ្ឌល។

**ចំណោទទី១**

| |
|---|
| ចូររកវិធីផ្សេងៗដើម្បីឱ្យបានប្រាក់ ៤៦០០៛ ដោយប្រើក្រដាសប្រាក់ ២០០០៛ ៥០០៛ និង២០០៛។ |

❖ ចំណោទនេះមានគោលបំណងជួយសិស្សឱ្យចេះស្រាវជ្រាវរកចម្លើយឱ្យបានច្រើន ចំពោះចំណោទខ្លះដែលមានចម្លើយច្រើន (គប្បីកុំឱ្យសិស្សយល់ច្រឡំថា គ្រប់ចំណោទមានចម្លើយតែមួយ ហើយដោះស្រាយបានតែម្យ៉ាង ឬប្រើរបៀបតែមួយ) រៀបចំចម្លើយ ទាំងឡាយរបស់ខ្លួនឱ្យមានរបៀប ព្រមទាំងបង្ហាញថាគេបានរកឃើញចម្លើយគ្រប់អស់ហើយ។

❖ លោកគ្រូ អ្នកគ្រូ គួរសាកល្បងឱ្យសិស្សរកវិធីដោះស្រាយដោយខ្លួនឯងតាមសមត្ថភាព និងតាមមធ្យោបាយផ្ទាល់របស់គេរៀងៗខ្លួន។ ប្រសិនបើលោកគ្រូ អ្នកគ្រូ មានការលំបាកក្នុងការរកវិធីដោះស្រាយយ៉ាងត្រឹមត្រូវ និងសមស្របដែរនោះ សូមអញ្ជើញអានការណែនាំ និងចម្លើយដូចតទៅ :

**ក. ការរៀបចំរបស់គ្រូ**

ចម្លងចំណោទដាក់ក្ដារខៀនមុនពេលបង្រៀន។

**ខ. លំនាំនៃការបង្រៀន**

__ដំណាក់ទី១ :__ អំណាន និងការយល់អត្ថន័យ

- ឱ្យសិស្សអានចំណោទនៅលើក្ដារខៀនដោយស្ងៀមស្ងាត់ និងដោយប្រុងប្រយ័ត្ន
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សអាន
- សួរ : "តើចំណោទនេះ គេឱ្យកូនធ្វើអ្វី?"
- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់ដោយសម្ដីរបស់គេផ្ទាល់ មិនឱ្យអានចំណោទឡើងវិញទេ
- ដើម្បីឱ្យដឹងថា សិស្សពិតជាយល់ខ្លឹមសារចំណោទ ត្រូវឱ្យសិស្ស២ ឬ៣នាក់ផ្ដល់ចម្លើយដោយផ្ទាល់មាត់ កត់ចម្លើយទាំងនោះដាក់លើក្ដារខៀន។

__ដំណាក់ទី២ :__ ការស្រាវជ្រាវលើកទី១ របស់សិស្ស

- រៀបសិស្សជាក្រុមពីរៗនាក់ និងត្រៀមធ្វើកិច្ចការលើក្រដាសព្រាង។

**គ្រូណែនាំ:** "ចូរកូនស្រាវជ្រាវ រិះរកឱ្យឃើញវិធីផ្សេងៗ ដើម្បីឱ្យបានប្រាក់ចំនួន ៤៦០០៛ ដោយប្រើក្រដាសប្រាក់ទាំងនេះ។ ចម្លើយទាំងអស់ត្រូវសរសេរដាក់លើក្រដាសព្រាង។"

- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សធ្វើការស្រាវជ្រាវ
- គ្រូត្រូវដើរពិនិត្យការងាររបស់សិស្ស ដើម្បីត្រៀមជ្រើសរើសអ្នកដែលត្រូវឡើងមកបង្ហាញការស្រាវជ្រាវរបស់គេនៅលើក្ដារខៀន ពេលធ្វើកំណែរួម (ត្រូវឱ្យសិស្សដែលមានចម្លើយខុសឡើងមកបង្ហាញមុនគេ)។

**<u>ដំណាក់ទី៣ :</u>** កំណែលើកទី១

- ចែកក្ដារខៀនជាពីរចំណែក។ មួយចំណែកសម្រាប់កត់ចម្លើយរបស់សិស្ស និងមួយចំណែកទៀតសម្រាប់គូរតារាងពេលធ្វើសំយោគ (ដូចគំរូខាងក្រោម)
- ឱ្យសិស្ស២ ឬ៣នាក់ឡើងមកសរសេរចម្លើយរបស់គេលើក្ដារខៀន
- សួរសិស្សថា : "តើមានកូនណារកឃើញចម្លើយផ្សេងទៀតទេ?"។ នៅរាល់ចម្លើយរបស់សិស្សត្រូវធ្វើការត្រួតពិនិត្យថា តើមាននៅលើក្ដារខៀនហើយឬនៅ? បើមិនទាន់មានទេ ត្រូវឱ្យសិស្សនោះឡើងមកសរសេរបន្ថែម។

* ក្នុងករណីដែលចម្លើយរបស់សិស្សណាមួយខុស ត្រូវឱ្យសិស្សទាំងអស់ពិនិត្យ និងធ្វើកំណែឱ្យបានត្រឹមត្រូវមុននឹងហៅសិស្សម្នាក់ទៀតឱ្យឡើងមកសរសេរចម្លើយលើក្ដារខៀន។

- បន្តសំណួរ : "តើយើងបានរកអស់លទ្ធភាពហើយឬនៅ? តើត្រូវធ្វើដូចម្ដេចដើម្បីឱ្យដឹងថា យើងបានរកឃើញគ្រប់ចម្លើយអស់ហើយ?"

**<u>ដំណាក់ទី៤ :</u>** ការស្រាវជ្រាវលើកទី២ របស់សិស្ស

- ឱ្យសិស្សពិភាក្សាក្នុងក្រុមបួនៗនាក់ ដើម្បីស្រាវជ្រាវរិះរកវិធីណាដែលអាចជួយឆ្លើយនឹងសំណួរខាងលើនេះបាន
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សផ្លាស់ប្ដូរយោបល់គ្នាក្នុងក្រុម ដោយសរសេរចម្លើយដាក់ក្រដាសព្រាង
- គ្រូដើរពិនិត្យការងាររបស់ក្រុមសិស្ស ព្រមទាំងជួយជំរុញឱ្យសិស្សពិនិត្យ និងតម្រៀបលទ្ធផលនៅលើក្ដារខៀន ដើម្បីឆ្លើយនឹងសំណួរចុងក្រោយនេះ។

**<u>ដំណាក់ទី៥ :</u>** កំណែរួមលើកទី២

- គ្រូធ្វើការបូកសរុបការស្រាវជ្រាវរបស់សិស្ស ព្រមទាំងជួយសិស្សឱ្យចេះរៀបចំបំរាប់ទាំងឡាយដោយគូរតារាង។

បើសិស្សមិនអាចរកឃើញទេ គ្រូត្រូវដឹកនាំសិស្សឱ្យចេះរៀបចំ កសាងជាតារាងដោយខ្លួនឯង រួចធ្វើការស្រាវជ្រាវដោយប្រើ និងបំពេញតារាងដូចខាងក្រោម :

| 2.000 | 500 | 200 |
|---|---|---|
| 2 | 0 | 3 |
| 1 | 4 | 3 |
| 1 | 2 | 8 |
| 1 | 0 | 13 |
| 0 | 8 | 3 |
| 0 | 6 | 8 |
| 0 | 4 | 13 |
| 0 | 2 | 18 |
| 0 | 0 | 23 |

ក្រោយពីបានរកចម្លើយសព្វគ្រប់អស់ហើយ គ្រូត្រូវដឹកនាំសិស្សឱ្យសង្កេតមើលកូឡោនក្រដាសប្រាក់ ៥០០៛ ដោយសួរថា : "តើកូនសង្កេតឃើញយ៉ាងដូចម្ដេច?"

- បំផុសឱ្យសិស្សឆ្លើយបានច្រើននាក់ ។

* បើសិស្សឆ្លើយមិនរួចទេ គ្រូត្រូវសួរបន្តទៀតថា : តើក្នុងកូឡោនក្រដាសប្រាក់ ៥០០៛គេអាចប្រើចំនួនសេសបានដែរឬទេ ពីព្រោះអ្វី?

- ឱ្យសិស្សពន្យល់ហេតុផលនេះឱ្យបានច្រើននាក់ (គេមិនអាចបាន ៦០០៛ទេ ព្រោះគ្មានក្រដាសប្រាក់ ១០០៛ ។ ដូចនេះ ក្នុងកូឡោននេះត្រូវប្រើចំនួនគូជានិច្ច) ។
- ដំណាក់ទី៦ : សន្និដ្ឋាន
- គ្រូបង្ហាញអត្ថបទ "គួរចងចាំ" ដោយរៀបរាប់ពន្យល់ ។

**គួរចងចាំ**

**ការរៀបចំស្រាវជ្រាវដោយប្រើតារាង អាចឱ្យយើងគេឃើញគ្រប់ចម្លើយទាំងអស់របស់ចំណោទ ហើយអាចបញ្ជាក់យ៉ាងច្បាស់ថា គ្មានចម្លើយណាផ្សេងទៀតទេ។**

- ឱ្យសិស្សចម្លងអត្ថបទ "គួរចងចាំ" ។

(នៅមានត)

លោកស្រី ម៉ឹន សារ៉ែន

# របៀប វិធីផ្ទាល់ខ្លួនរបស់គ្រូក្នុងការបង្រៀន

មុននឹងឈានចូលទៅដល់ប្រធានបទខាងលើ ខ្ញុំសូមបង្ហាញជូនពាក្យ និងឃ្លាមួយចំនួនពាក់ព័ន្ធនឹងសីលធម៌វិជ្ជាជីវៈ ដែលខ្ញុំនៅចាំបានពីការបង្រៀនរបស់សាស្ត្រាចារ្យពេលដែលខ្ញុំជាគរុសិស្សនៅមហាវិទ្យាល័យគរុកោសល្យផ្នែកខាងជើងនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៦០។ ក្នុងពេលនោះ សាស្ត្រាចារ្យបានផ្ដល់មេរៀនភាគច្រើន ទាំងការសរសេរ ការនិយាយ និងការពន្យល់សុទ្ធសឹងតែជាភាសាបារាំងទាំងអស់ ហើយពេលនេះខ្ញុំសូមប្រែសម្រួលដូចតទៅ :

- គ្រូបង្រៀន គឺជាមនុស្សម្នាក់ដែលរដ្ឋប្រគល់ការទុកចិត្តក្នុងការបង្ហាត់បង្រៀនកុមារ (L’instituteur est un homme à qui l’Etat confie l’instruction des enfants)
- កុមារទាំងនេះ សុទ្ធសឹងជាសត្វលោកដែលមានតម្លៃយ៉ាងពិសិដ្ឋចំពោះជាតិ មាតុភូមិ (Ces enfants sont des êtres si chers, si précieux pour la Nation et la Patrie)
- ប្រសិនបើនិយោជិតម្នាក់នៃសេវាផ្សេងៗធ្វេសប្រហែស ឬពាយងាយក្នុងការងារ គឺសម្ភារៈ ឬទព្វសម្ភារៈទេដែលត្រូវខូចបង់ (Si un employé des autres services néglige son travail ce sont des matériels qui sont lésés) ។

ពាក់ព័ន្ធនឹងចិត្ត-គរុកោសល្យ ខ្ញុំសូមលើកយកឃ្លាមួយរបស់សាស្ត្រាចារ្យជាភាសាបារាំងមកបកប្រែ និងសុំធ្វើការបកស្រាយជូនដូចតទៅ :

“Enseigner peu mais bien” : បង្រៀនតិច តែបង្រៀនល្អ ចង់ប្រាប់លោកគ្រូ អ្នកគ្រូ ថា សុំបង្រៀនយឺតៗខ្លីៗ ហើយតិច តែបង្ហាត់បង្ហាញឱ្យបាន ច្បាស់លាស់ កុំឱ្យសិស្សភ័ន្តច្រឡំ ឬនៅស្រពិចស្រពិល។

ឃ្លាខាងលើនេះ មានអត្ថន័យប្រហាក់ប្រហែលនឹងឃ្លាខាងក្រោម ដែលសាស្ត្រាចារ្យបានស្រង់ពាក្យរបស់គរុ-កោសល្យវិទូជាតិបារាំងម្នាក់មកបញ្ជាក់ និងពន្យល់ : មនុស្សដើរប៉ុងពៀចម្នាក់ តាមផ្លូវត្រង់មកដល់ទិសដៅមុន អ្នករត់ម្នាក់ដែលវង្វេងផ្លូវ (Un boiteux dans un chemin droit arrive avant un coureur qui s’égare) ។

ចង់និយាយថា ការបង្រៀនដោយគ្មានការរៀបចំទុកជាមុន គឺចេះតែថាម្ដងយ៉ាងនេះ ម្ដងយ៉ាងនោះ មិនប្រាកដថាចង់និយាយពីអ្វីហើយជួនកាលនិយាយវែង លឿនមិនច្បាស់លាស់ សិស្សពុំអាចចាប់បាន ឬយល់បានដែលផ្ទុយពីអ្នកដែលបង្រៀនយឺតៗ មានសៀវភៅតែងការបង្រៀនអាចបង្រៀនមួយជំហានទៅមួយជំហានច្បាស់លាស់តាមប្លង់ដែលបានរៀបចំទុកជាមុន សិស្សអាចស្ដាប់បានឆាប់យល់ នោះហើយដែលលោកប្រៀបធៀបទៅនឹងជនពិការជើង តាមផ្លូវត្រង់ទៅដល់ទិសដៅមុនអ្នករត់ដែលវង្វេងផ្លូវ តែការបង្រៀនយឺតៗនោះក៏ត្រូវប្រមាណទៅនឹងរយៈពេលនៃកម្មវិធីសិក្សាផងដែរ។

ដូច្នេះហើយបានជាគរុកោសល្យវិទូនិយាយថា "ការផ្ទេរចំណេះដឹងឱ្យសិស្សពុំមែនដូចការបញ្ច្រកទឹកចូលក្នុងដបឱ្យឆាប់តែបានពេញនោះទេ"។

កុមារត្រូវតែសកម្ម ថ្នាក់រៀនត្រូវតែរស់រវើក (Les enfants doivent être actifs. La Classe doit toujours être vivante)។ "ក្មេងត្រូវតែសកម្ម ថ្នាក់រៀនត្រូវតែរស់រវើក" នោះពុំមែនបានន័យថា ក្មេងប្រឡែងរុញច្រាន

គ្នា ស្រែកហ៊ោកញ្ជ្រៀវពេញថ្នាក់ដោយឥតមានវិន័យនោះទេ។ រស់រវើកបែបនេះជាការរស់រវើកអវិជ្ជមាន។ ចង់និយាយថា ជាមួយគ្រូដែលប៉ិនប្រសប់ពន្យល់ និងសួរ សិស្សលើកដៃដណ្ដើមគ្នាចង់ឆ្លើយ។ សិស្សស្វាហាប់ រីករាយ ក្លាហាន ហ៊ានឡើងទៅមុខក្ដារខៀនតាមការចង្អុលហៅរបស់គ្រូ។ ខាងក្រោមនេះ ជាប្រធានបទដែលខ្ញុំចង់ជម្រាបជូនលោកគ្រូ អ្នកគ្រូទាំងអស់អំពីរបៀបវិធីផ្ទាល់ខ្លួនរបស់គ្រូក្នុងការបង្រៀន ជាពិសេសលោកដែលជាសិក្ខាបនធារីផ្ទាល់តាមថ្នាក់នៃគ្រឹះស្ថានសិក្សានានាទូទាំងប្រទេស។

ការជម្រាបជូននេះ គឺខ្ញុំគ្រាន់តែចង់រំលែកការចេះដឹងដែលខ្ញុំចងចាំបានកន្លងមក តាមការបង្ហាត់បង្ហាញពីសាស្ត្រាចារ្យមុនៗ និងការពិសោធន៍ផ្ទាល់ខ្លួនខ្លះៗប៉ុណ្ណោះ។

បុគ្គលិកសិក្សាទាំងអស់ដែលធ្លាប់បង្រៀន ជាពិសេសលោកគ្រូ អ្នកគ្រូ ដែលធ្លាប់បានឆ្លងកាត់ការរៀនសូត្រ ឆ្លងវគ្គបណ្ដុះបណ្ដាលនៅសាលាគរុកោសល្យ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ឬរៀននៅមហាវិទ្យាល័យគរុកោសល្យនានាពីសម័យមុនៗ ក៏ដូចជាសម័យក្រោយ ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ តែងតែមានបទពិសោធន៍គរុកោសល្យគ្រប់ៗគ្នា គ្រាន់តែច្រើន និងតិចប៉ុណ្ណោះ។

ថ្វីបើលោកទាំងអស់នោះធ្លាប់បានឆ្លងកាត់ការសិក្សារយៈពេលដូចគ្នា នៅសាលាគរុកោសល្យដូចគ្នាក្ដី គុណភាព និងការចងចាំរបស់សិស្សដែលគាត់បង្រៀន ពុំសូវបានផលល្អ ឬចងចាំបានយូរដូចគ្នាទាំងអស់ទេ បើសិស្សទាំងនោះទទួលការបង្ហាត់បង្រៀនពីលោកគ្រូ អ្នកគ្រូខុសគ្នា។ ភាពខុសគ្នានេះ មិនទាន់គិតដល់ឆន្ទៈ ការយកចិត្តទុកដាក់ ឬមិនយកចិត្តទុកដាក់របស់គ្រូនៅឡើយផងក្នុងការបង្ហាត់បង្រៀនសិស្ស។ ឧទាហរណ៍ៈ លោកគ្រូ ២នាក់ចេញពីមហាវិទ្យាល័យគរុកោសល្យដូចគ្នាទៅបង្រៀននៅគ្រឹះស្ថានសិក្សាមួយជាមួយគ្នា បង្រៀនក៏រឹតថ្នាក់ដូចគ្នា គ្រូទាំង២នាក់នេះមានឆន្ទៈ និងយកចិត្តទុកដាក់ដូចគ្នា តែមានភាពខុសគ្នាអំពីល្បិចរបៀប និងវិធីផ្ទាល់ខ្លួន។

ល្បិច របៀប និងវិធីបង្រៀននេះ ពុំមានចែងក្នុងទ្រឹស្ដីបទទេ គ្រូត្រូវតែឈ្លាសវៃ រកមធ្យោបាយ រកទីកធ្វើយ៉ាងណាដើម្បីភ្ញោចអារម្មណ៍សិស្សដោយរកឃ្លា ឬពាក្យដែលជូនរណ្ដំគ្នាខ្លះៗ មិនបាច់ដល់ទៅកំណាព្យកាព្យឃ្លោងដែលមានពាក្យចុងជួនត្រឹមត្រូវនោះឡើយ តែបើបានត្រឹមត្រូវវារឹតតែប្រសើរណាស់ទៅទៀត គឺគ្រូត្រូវបង្កើតដោយខ្លួនឯង ឬចម្លងអ្វីដែលត្រឹមត្រូវពីសាស្ត្រាចារ្យ គ្រូបង្រៀនមុនៗដែលបាននិយាយ និងសរសេរទុកក្នុងឯកសារណាមួយ។

ពាក្យដែលមានចុងជួន រណ្ដំគ្នា ឬកំប្លែងធ្វើឱ្យសិស្សចូលចិត្ត និងឧស្សាហ៍ធ្វើលំនឹក ដោយយកមកទន្ទេញ សូត្រលេងបង្គួតមិត្តភក្តិ ដែលជាហេតុធ្វើឱ្យពាក្យ ឬឃ្លាទាំងនោះនៅថ្មីៗក្នុងខួរក្បាល ឬក្រសែភ្នែករបស់គេជាប់ជានិច្ច។

(នៅមានត)

**លោក គឹម ប៊ុនសាន**

អនុ.នា.ហិរញ្ញវត្ថុ នៃក្រសួង អ.យ.ក.

# សត្វក្អែក និងមេមាន់

ជាយូរលង់ណាស់មកហើយ មានសត្វក្អែកមួយចង់រៀបការជាមួយមេមាន់។ វាបានប្រគល់ចិញ្ចៀនបញ្ចាំចិត្តមួយវង់ ធ្វើអំពីមាសសុទ្ធយ៉ាងល្អទៅមេមាន់។ ថ្ងៃបន្ទាប់មក មេមាន់ក៏បានជួបនឹងមាន់គកមួយ។ មាន់គកឃើញមេមាន់ពាក់ចិញ្ចៀនបញ្ចាំចិត្តរបស់សត្វក្អែក ក៏សួរមេមាន់ថា :

- អ្នកពាក់ចិញ្ចៀននេះមានន័យយ៉ាងណា?
- សត្វក្អែកបានឱ្យមកខ្ញុំ ព្រោះគាត់ចង់រៀបការជាមួយខ្ញុំ។ មេមាន់ឆ្លើយ។
- ស្អីហ្នឹង! មាន់គកស្រែក។ អ្នកណាដែលឮសត្វក្អែករៀបការជាមួយមេមាន់... គួរចំឡែកមែន!។
- គ្មានអ្វីប្លែកទេ សត្វក្អែកធ្វើបាន។ មេមាន់ឆ្លើយ។ គេនឹងរៀបការជាមួយខ្ញុំក្នុងពេលឆាប់ៗនេះ។
- "បើសិនជាសត្វក្អែកចង់រៀបការជាមួយអ្នកមែន តេមិនមែនឱ្យចិញ្ចៀនបញ្ចាំចិត្តមានតម្លៃថោកដូចនេះទេ។ ចិញ្ចៀននេះធ្វើអំពីទង់ដែង" ។ មាន់គកនិយាយ។
- មិនមែនធ្វើអំពីទង់ដែងទេ! ចិញ្ចៀននេះពិតជាធ្វើអំពីមាសសុទ្ធ។
- អ្នកដឹងទេ ខ្ញុំមានបទពិសោធន៍មួយ។ ខ្ញុំជឿថា អ្នកមិនហ៊ានធ្វើតាមខ្ញុំទេ។ បើចិញ្ចៀននេះពិតជាមាសសុទ្ធមែន កាលណាអ្នកបោះវាទៅឆ្ងាយ វានឹងហោះវិលមករកអ្នកវិញ។ តែបើវាធ្វើអំពីទង់ដែង វាច្បាស់ជាមិនវិលមករកអ្នកវិញឡើយ។ តើអ្នកហ៊ានសាកល្បងជាមួយខ្ញុំទេ?

មេមាន់ជឿជាក់លើខ្លួនឯង ក៏បោះចិញ្ចៀនទៅឆ្ងាយអស់មួយទំហឹង រួចរង់ចាំចិញ្ចៀនហោះត្រឡប់មកវិញ។ វាចាំបាត់... ចាំបាត់... មាន់គកសើច ហើយស្រែកថា :

- ខ្ញុំនិយាយហើយថា ចិញ្ចៀននេះធ្វើអំពីទង់ដែងមានតម្លៃថោក។ អ្នកឃើញទេ វាមិនវិលមកវិញឡើយ។ ចុះហេតុអ្វីបានជាអ្នកមិនរៀបការជាមួយខ្ញុំវិញ? ខ្ញុំនឹងឱ្យចិញ្ចៀនធ្វើអំពីមាសសុទ្ធដល់អ្នក។

ក្រោយពេលបោះចិញ្ចៀនចោល មេមាន់មានការព្រួយបារម្ភយ៉ាងខ្លាំង។ ប៉ុន្តែវាគិតថា សត្វក្អែកច្បាស់ជាមិនដឹងថាមានហេតុការណ៍អ្វីកើតឡើងឡើយ។

ចៃដន្យពេលនោះ សត្វចាបបានឃើញមេមាន់បោះចិញ្ចៀនក្អែកចោល។ វាក៏ហើរទៅតាមពាំយកចិញ្ចៀននោះហើយរាយការណ៍ប្រាប់សត្វក្អែកតាមដំណើររឿងមួយរំពេច។

ពេលស្ដាប់ហើយ សត្វក្អែកខឹងយ៉ាងខ្លាំង។ វាហើរទៅរកមេមាន់ភ្លាម ហើយសួរថា :

- ឯណាចិញ្ចៀនបញ្ចាំចិត្តខ្ញុំ?
- អូ!... សូមទោសណាំ ចិញ្ចៀនអ្នកជ្រុះបាត់ទៅហើយ នៅពេលដែលមាន់គករត់ដេញខ្ញុំ។ មេមាន់ឆ្លើយដោយភ័យ។
- ខ្ញុំមិនជឿអ្នកទេ! សត្វក្អែកស្រែក។ ខ្ញុំដឹងថា អ្នកបោះចិញ្ចៀនខ្ញុំចោល ដោយចង់រៀបការជាមួយមាន់គក។

តាមពិត មេមាន់គ្មានគំនិតចង់រៀបការជាមួយមាន់តកទេ។ ប៉ុន្តែហេតុអ្វីក៏វាធ្វើដូច្នេះ? វានឹកស្តាយក្រោយយ៉ាងខ្លាំង ហើយគិតថា សត្វក្អែកអស់ជំនឿទុកចិត្តលើវាទៀតហើយ។

- ខ្ញុំឈប់រៀបការជាមួយអ្នកឯងហើយ។ អ្នកឯងមានចិត្តមិនស្មោះត្រង់ជាមួយខ្ញុំ។ ចាប់ពីពេលនេះទៅ យើងនឹងក្លាយទៅជាសត្រូវនឹងគ្នា។ ខ្ញុំនឹងលួចឆក់កូនអ្នកជាអាហារ រហូតដល់អ្នកប្រគល់ចិញ្ចៀនឱ្យខ្ញុំវិញ។ ក្អែកពោលដោយកំហឹង។

មេមាន់ដើររកចិញ្ចៀនគ្រប់ទីកន្លែង។ វាកកាយដីក្រុកៗ វិលជុំវិញកន្លែងដែលវាបោះចិញ្ចៀនចោល តែវារកមិនឃើញ។ មាន់តកឃើញមេមាន់កាយដីរកចិញ្ចៀនក៏សើច ហើយពោលថា :

- ឥឡូវ អ្នកជឿខ្ញុំហើយឬនៅ ថាចិញ្ចៀនបញ្ចាំចិត្តរបស់សត្វក្អែកពិតជាមិនមែនធ្វើអំពីមាសសុទ្ធ។ យកល្អអ្នកទទួលចិញ្ចៀនបញ្ចាំចិត្តរបស់ខ្ញុំ ហើយយល់ព្រមរៀបការជាមួយខ្ញុំវិញទៅ។

មេមាន់មិនហ៊ានរស់នៅតែឯកឯង ព្រោះភ័យខ្លាចសត្វក្អែកធ្វើបាប។ វាក៏សុខចិត្តរៀបការជាមួយមាន់តក។

ប៉ុន្តែមេមាន់នៅតែខំកកាយដីរកចិញ្ចៀនសងសត្វក្អែកវិញ គ្រប់ពេលវេលា។ វារកពុំឃើញសោះ។ ដូចនេះហើយបានជាមេមាន់នឹងសត្វក្អែកនៅតែជាសត្រូវនឹងគ្នារហូតមកដល់សព្វថ្ងៃនេះ៕

សម្រួលពីរឿងព្រេងបរទេស
ដោយលោកស្រី ឃួរ ស៊ីរី

## អាលោវឆ្កែខ្ញុំ

អាលោវឆ្កែខ្ញុំ មិនតូចមិនធំ ទ្រង់ទ្រើសជាងថ្នា
ត្រចៀកកញ្ជ្រឹប មុខស្រួចដូចស្វា កន្ទុយដូចស្លា
រោមដូចសំឡី។

ឆ្កែខ្ញុំដឹងណាស់ ស្គាល់មនុស្សក្នុងផ្ទះ និងគោក្របី
មិនព្រុសមិនដេញ មិនដែលធ្វើអ្វី មនុស្សសត្វដទៃ
គ្រហឹមខាំផង។

លោតអរទទាក់ នឹងមនុស្សខ្ជិនខ្ជាក់ អាលោវផ្សៀងផ្សង
ទោះបីវាព្រុស នោះតែម្តងៗ ត្រូវដឹងទំនង
នឹងម្ចាស់ស្រីវា។

ម្ល៉ោះហើយអ្នកផ្ទះ រលាំងរលះ ដោយចិត្តសទ្ធា
ធ្វើបុណ្យឱ្យទាន ពុំមានរួញរា ទាំងគាចទាំងជា
ធ្វើដាច់អាល័យ។

ម៉ុត សំអិត (១៨៨០-១៩៣១)

មូលវិជ្ជាខេមរភាសា




# ដើមឫស្សីស្រុក

(បទកាកគតិ)

ឫស្សីព្រៃស្រុក ប្រយោជន៍ច្រើនមុខ តាមតែយើងច្នៃ
ធ្វើត្បាល់កិនស្រូវ ទ្រុងទ្រូក្រុងខៃ ផ្តិតដួនបាំងថ្ងៃ
លប៊ីបលាន់អង្រុត ។
ឈ្នាងជញ្ជាត់ត្រី កញ្ជើតៅល្អី តោកស្តុកស្រូវទុក
ជាលស៊ុមក្រុងមាន់ របារជង្រុក ព្រួលវាយរាំងមុខ
ប្រើសជងសន្ទូច ។
ត្រដោកឫស្សី តម្បូតអាំងត្រី រនាបក្រាលទូក
ដង្ហក់ដេញចាប ចង្កឹះជើងធូប កញ្ជែដុចជ្រូក
រង្វេលទ្រឆ្នាំង ។
ខ្នារជងកណ្ដប កន្ទ្រងប្រហុក ចង្អាក់ចេកអាំង
បង្គីដងរែក កាំភ្លោះផ្លូងផាំង ដេញបង្អើលខ្លាំង
កន្ទ្រកធ្នូស្នា ។
ច្រមសែនអ្នកតា ទ្រូឆ្នុករបារ ប្រដើសជាស្ពាន
កឡោបីប៉ោអ៊ី ទម្រទ្រទៀន ក្រឡានត្រកមៀន
ថូឈើចាក់ធ្មេញ ៕

លោក ជួប ហុតហេង
អនុវិ.ព្រែកស្បូវ
ស្រុកស្ទឹងសែន ខេត្តកំពង់ធំ

# ផលប៉ះពាល់នៃឥទ្ធិពលគ្រឿងញៀន (ត)

ប្រទេសកំពុងអភិវឌ្ឍ ជាទីសំចតនៃពួកវា
នាំចូលស្តុកទុកគ្រប់វេលា បង្កប់ភ្នាក់ងារចែកផ្សព្វផ្សាយ ។
ធ្វើឱ្យយើងមានក្តីបារម្ភ ខ្លាចរីករាលធំសុសសាយភាយ
ពេញទាំងពិភពនោះមិនងាយ បំបែកសំពាយឬទប់ស្កាត់ ។
ម្យ៉ាងបើគ្រឿងញៀនបៀតបៀនចូល ពិបាកសម្រួលឬកំចាត់
រារាំងមិនឱ្យវាឆ្លងកាត់ ឬលុបបំបាត់ឱ្យសោះសូន្យ ។
គ្រឿងញៀនកំពុងក្លាយជាក្តី បារម្ភភិតភ័យម្តាយជីដូន
អាណាព្យាបាលបងនិងប្អូន ខ្លាចកូនចៅខ្លួនលង់នឹងវា ។
ព្រោះកូនចៅចេញទៅក្រៅផ្ទះ មិត្តភក្តិច្រើនណាស់មានល្អជា
មានខូចមានកាចមានពាលា មានមិត្តមានមារចាំណែនាំ ។
ជូនជួបអ្នកល្អបវរក្រៃ អូសទាញដឹកដៃឱ្យខិតខំ
រៀនសូត្រព្យាយាមចិត្តបន្ទំ ឱ្យបានស្អាតស្អំសមប្រកប ។
ជូនជួបអ្នកខូចខិលឬស្បា យកអាភៀនម៉ាឬស្រាដប
មកដាក់ពង្វក់ឱ្យខ្វាចខ្វប ឃើញតែកញ្ចប់ស្រក់ទឹកមាត់ ។
ជូនជួបអ្នកខូចកាងឡូឡា បង្ខំអាជ្ញាប្រើរំពាត់
កាំបិតដំបងវាយសំឡុត ឱ្យភ័យតក់ស្លុតធ្វើតាមវា ។
កូនចៅយើងល្អតែពេលចូល ក្នុងក្រុមប្រមូលពួកពាលា
ត្រូវធ្វើដូចគេទើបសុខជា កាយមិនគ្រាំគ្រាគេធ្វើបាប ។
ម៉ែឪមិនបានតាមដឹតដល់ ព្រោះជាប់រវល់ដូចដឹងស្រាប់
ការងាររាជការព្រឹកថ្ងៃយប់ រកស៊ីសព្វគ្រប់ដើម្បីកូន ។
ទឹកស្មានថាគេទៅសាលា រៀនសូត្រសិក្សាលេខនព្វន្ត
អក្សរសិល្ប៍សាស្ត្រមិនទម្រន់ ស៊ូទ្រាំរែកពុនតែខ្លួនឯង ។
ព្រោះខ្លាចរំខានដល់រូបកូន ប្រាជ្ញាអាប់ឱនទឹកគិតឆ្វេង
ប្រឡងមិនជាប់ខ្មាសពួកក្មេង ក្នុងភូមិគេតែងរៀនគ្រប់គ្នា ។
ម្យ៉ាងព្រួយខ្លាចកូនជាចំណាប់ ត្រូវពួកវាចាប់គំរាមទារ
ឱ្យយកប្រាក់បង់សូកលស់លា ទៅឱ្យក្រុមវាទើបរួចខ្លួន ។

| | |
|---|---|
| ឬក៏ឱ្យកូនលួចពីម្ដាយ | ដោយចាញ់ឧបាយកលផ្ទួនៗ |
| លុយកាក់ប្រាក់កាសឬទ្រព្យធន | ហ៊ានលាក់បំពួនយកឱ្យគេ ។ |
| ដើម្បីដោះដូរនឹងគ្រឿងញៀន | ព្រោះដល់ពេលឃ្លានមិនខ្លាចទេ |
| កុំថាលួចលាក់គ្មានទំនេរ | ប្លន់ក៏ហ៊ានដែរឱ្យតែបាន ។ |
| ម្យ៉ាងទៀតមេឪដែលឧត្ដម | បើសិនកូនសុំមិនហ៊ានខាន |
| មានតិចឱ្យតិចតាមធនធាន | ស៊ូទ្រាំអត់ឃ្លានខ្លួនឯងចុះ ។ |
| គ្រឿងញៀនកំពុងក្លាយជាក្ដី | បារម្ភភិតភ័យជនស្រីប្រុស |
| ខ្លាចរងគ្រោះថ្នាក់ខូចកេរ្តិ៍ឈ្មោះ | ដោយការទាញអូសរបស់វា ។ |
| ព្រោះថាមនុស្សយើងពិតជាដឹង | គ្រឿងញៀនស្រវឹងថ្នាំយ៉ាម៉ា |
| បានចូលក្នុងខ្លួននៅពេលណា | ឱ្យអន្ទះសារពិបាកទ្រាំ ។ |
| ប៉ុន្តែក្រែងហាមចិត្តមិនបាន | ចង់សាកចង់កាន់ចង់ញីញ៉ាំ |
| ចង់ភ្លក្សលេងល្បែងភក់ជ្រាំ | គ្មានចិត្តស្អាតស្អំប្រមាថខ្លួន ។ |
| ឬក៏ការញៀនដោយមិនដឹង | ពុលឬស្រវឹងនៅក្រៅក្បួន |
| ដោយអ្នកជិតខាងលាក់បំពួន | បង្ខូចជីពជន្មឱ្យវង្វេង ។ |
| បន្លំដាក់ក្នុងគ្រឿងអាហារ | ឈ្លុយឆ្លាញ់ពិសាមិនមែនលេង |
| ស្មានថាគ្មានរឿងអ្វីដែលផ្សេង | ហូបចុកឥតក្រែងគ្មានសំចៃ ។ |
| ដូចជានៅក្នុងជាតិសុរា | តែ ស្ករ ភោគ្គាឬបារី |
| មិនបានពិនិត្យគិតសង្ស័យ | ថាគ្មានរឿងអ្វីពេលបរិភោគ ។ |
| ឬមាននៅក្នុងជាតិកាហ្វេ | ឆុងដាក់លាយមេច្រើនគគោក |
| ផឹកហើយនឹងញៀនគិតពីលោក | មិនចង់ឡើងក្រោកដើរទៅណា ។ |
| ភ្លេចបាយភ្លេចទឹកនឹកតែវា | ព្រឹកឡើងស្ពុះស្ពារភ្លេចធ្វើការ |
| មិនទាន់បានផឹកដូចសព្វគ្រា | កិច្ចការពិតជាធ្វើមិនកើត ។ |
| រសោះដៃជើងឆ្អឹងរលៀក | ឬហ៊ឹងត្រចៀកស្រាលខ្លួនកើត |
| ព្រីលស្រវាំងភ្នែកដើរស្លក់ស្លើត | ត្បូងជើងលិចកើតលែងស្គាល់ទិស ។ |

( នៅមានត)

លោក ឃាស់ ម៉ូចតេរ៉ា
អធិការប.ឋ.ស. មន្ទីរអ.យ.ក.



# រឿងព្រេងអូរជាលមាស ភូមិស្វាយអង្គោល ភូមិស្រីបណ្ឌិត ខេត្តតាកែវ

ដោយយល់ឃើញថា រឿងព្រេងនេះមានទាក់ទងនឹងប្រវត្តិនគរគោកធ្លក ពិសេសខេត្តតាកែវដែលជាខេត្តមួយក្នុងកម្ពុជរដ្ឋមានអាយុចាស់ជាងគេ និងមានបុរាណស្ថានច្រើន ព្រោះថាទាំង២៤ខេត្តរាជធានីសព្វថ្ងៃមានតែខេត្តនេះទេដែលគេហៅតា។ ដំណើររឿងមានដូចតទៅ :

នៅឃុំស្លា ស្រុកសំរោង ខេត្តតាកែវ មានអូរ និងភូមិមួយមានឈ្មោះដូចខាងលើ។ បានជាមានឈ្មោះដូច្នេះ ព្រោះមានរឿងដំណាលត១គ្នាមកថា :

កាលរាជ្យស្ដេចស៊ីវណ្ណា សោយរាជ្យនៅអង្គរបុរីនោះមានព្រះអនុជប្រុសមួយព្រះអង្គ ទ្រង់ព្រះនាមស្រីបណ្ឌិត។ ព្រះអនុជអង្គនេះបានប្រព្រឹត្តសហាយស្មន់នឹងព្រះអគ្គមហេសីស្ដេចស៊ីវណ្ណា ព្រះរាមថ្លៃ។ លុះស្ដេចស៊ីវណ្ណា ទ្រង់ជ្រាបរឿងនេះ ទ្រង់បង្គាប់ឱ្យសម្លាប់ស្រីបណ្ឌិតជាព្រះអនុជ។ ស្រីបណ្ឌិត បានជ្រាបថា ស្ដេចជាព្រះរៀមប្រុងនឹងសម្លាប់ ក៏រៀបព្រះដំណើរលបរត់គេចចេញពីព្រះដំណាក់ដោយច្រកមាស ២ជាល រែករត់ចេញទៅខាងទិសនិរតី។ លុះស្ដេចស៊ីវណ្ណា ទ្រង់ជ្រាបថា ស្រីបណ្ឌិតរត់ចេញ ហើយក៏លើកពលចេញតាមទៅ។ ស្រីបណ្ឌិត គេចបាត់ខ្លួនត្រង់ភូមិចកយុល ក្នុងឃុំពន្លៃ។ ស្ដេចស៊ីវណ្ណា រកពុំឃើញបានឈប់សម្រាកទ័ពនៅទួលមួយ ទីទួលនោះគេហៅថា ទួលស្ដេចគង់ ជាប់មកដល់សព្វថ្ងៃ។ លុះស្ដេចគង់នៅទីនោះយូរបន្តិចទ្រង់ដំណឹងថា ស្រីបណ្ឌិត រត់ទៅដល់បឹងមួយនៅខាងលិចឃុំព្រៃផ្ដៅ។ ស្ដេចស៊ីវណ្ណា ក៏លើកទ័ពតាមទៅទៀត។ ស្រីបណ្ឌិតជ្រាបថា ទ័ពស្ដេចតាមមកជិតណាស់ហើយ ណាមួយធ្ងន់នឹងមាសពីរជាលដែលរែកផង ក៏ត្រវែងមាសពីរជាលនោះនៅក្បែរអូរនោះទៅ ហើយកាច់មែកស្វាយមួយមែកដោតជាគោលចំណាំកន្លែងទុកមាសនោះ ហើយស្រីបណ្ឌិតក៏រត់ទៅពួននៅភូមិមួយខាងអាគ្នេយ៍ ភ្នំជីសូរ។ ស្ដេចស៊ីវណ្ណា តាមរកពុំឃើញក៏លើកទ័ពត្រឡប់ទៅអង្គរបុរីវិញ។

លុះដល់ស្រុកសាន្តត្រាណ ស្រីបណ្ឌិត ក៏ទៅរកមាសត្រង់អូរនោះ តែរកពុំឃើញ។ ឯគោលមែកស្វាយដែលដោតចំណាំនោះនៅរស់ដដែល។ ស្វាយនោះ អ្នកស្រុកហៅថា ស្វាយគោល។ អូរនោះថាជាអូរជាលមាស ភូមិនោះថាភូមិស្រីបណ្ឌិត ជាប់មកដល់សព្វថ្ងៃ តែសព្វថ្ងៃនេះហៅក្លាយមកជាស្វាយអង្គោល។ អូរនោះហៅថា អូរជាលមាស ភូមិនោះហៅថា ភូមិស្រីបណ្ឌិតដដែល ៕

**លោក ចែម ផាន**

ទំព័រស្ត្រី

# គោលនយោបាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ

## ១.សេចក្តីផ្តើម

គោលនយោបាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការនេះរៀបចំចងក្រងឡើងដោយនាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានកិច្ចសហប្រតិបត្តិការពីមន្ត្រីនៅគ្រប់នាយកដ្ឋានរបស់ក្រសួង។ ឯកសារនេះផ្អែកលើការពិភាក្សាពិគ្រោះយោបល់ក្នុងរាជធានីភ្នំពេញ ជាមួយបុគ្គលិកតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-រាជធានី ការិយាល័យអប់រំ យុវជន និងកីឡាស្រុក-ខ័ណ្ឌ គ្រូបង្រៀន គ្រូអប់រំក្រៅប្រព័ន្ធ និងប្រធានការិយាល័យជាច្រើនរូបនៃគ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាមកពីបណ្តាខេត្ត-រាជធានីចំនួន៦។ សិស្ស និងអ្នកអាណាព្យាបាលសិស្ស ព្រមទាំងអ្នកផ្ទុកមេរោគអេដស៍ ក៏ត្រូវបានលើកទឹកចិត្តឱ្យបញ្ចេញទស្សនៈ យោបល់ និងការយល់ឃើញរបស់ពួកគេ នៅក្នុងគោលនយោបាយនេះផងដែរ។

ក្រុមការងារបានប្រមូលមតិយោបល់ជាច្រើន តាមរយៈសិក្ខាសាលាចំនួនពីរលើក ដែលមានការចូលរួមពីបុគ្គលិកមន្ត្រីរាជការតាមក្រសួង មកពីបណ្តាខេត្ត រាជធានីភ្នំពេញ និងទីភ្នាក់ងារមកពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ។ ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព័ត៌មាន មតិយោបល់ និងសំណូមពរប្រកបដោយអត្ថប្រយោជន៍ទាំងឡាយរបស់សិស្ស និស្សិត លោក លោកស្រីទាំងអស់។

### <u>គោលនយោបាយនៅកន្លែងធ្វើការ</u>

មេរោគអេដស៍ជាបញ្ហានៅកន្លែងធ្វើការ។ មេរោគអេដស៍ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើពិភពការងារ ដោយកាត់បន្ថយការផ្គត់ផ្គង់កម្លាំងពលកម្ម ការបង្កើនការចំណាយលើកម្លាំងពលកម្ម ការកាត់បន្ថយផលិតភាព ការគំរាមកំហែងដល់ជីវភាពរស់នៅរបស់អ្នកប្រើកម្លាំងពលកម្ម និងការប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាន។ វិបាកបណ្តាលមកពីមេរោគអេដស៍ប៉ះពាល់ខ្លាំងបំផុតក្នុងចំណោមក្រុមមនុស្សងាយរងគ្រោះ រួមមានស្ត្រី និងកុមារ និងធ្វើឱ្យមានវិសមភាពកាន់តែខ្លាំងក្នុងសង្គម។

កន្លែងធ្វើការគឺជាសហគមន៍ ជាទីដែលមនុស្សមកធ្វើការជាមួយគ្នា ជួបប្រាស្រ័យទាក់ទងគ្នា និងរៀនពីគ្នាទៅវិញទៅមក។ ដូចនេះ កន្លែងធ្វើការអាចជាកន្លែងដ៏ល្អសម្រាប់បង្ការឆ្លងមេរោគអេដស៍ ផ្តល់ការថែទាំ និងគាំទ្រ តាមរយៈកម្មវិធីផ្សេងៗដូចជាការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលសុខុមាលភាព និងសុវត្ថិភាព។ កន្លែងធ្វើការគឺជាកន្លែងដែលបទដ្ឋានសមស្របត្រូវបានកំណត់សម្រាប់លក្ខខណ្ឌការងារ ទំនាក់ទំនងការងារ និងការការពារសិទ្ធិរបស់អ្នកធ្វើការ។

សាលារៀនគឺជាកន្លែងធ្វើការពិសេសមួយ។ បន្ថែមលើសិទ្ធិរបស់បុគ្គលិកសិក្សា សាលារៀនក៏ត្រូវយកចិត្តទុកដាក់ដល់សិទ្ធិរបស់កុមារផងដែរ។ នៅពេលបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងធំជាងគេបំផុត។ ក្រសួងមាន

បុគ្គលិកចំនួនជាង ១០៤ ០០០នាក់ (បុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន) ហើយផ្តល់សេវាអប់រំតាំងពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សាដល់ប្រជាជនកម្ពុជាជាង ២៥ភាគរយ ។

## ២-ការអនុវត្តគោលនយោបាយ

### ២.១ គោលដៅ និងគោលបំណង

